# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និង អក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ លោក ភិយ-ប៊ុក
ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកសាសនាៈ ព្រះទេពសត្ថា ស៊ូរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| លោក ភិយ-ប៊ុក ក្រមការ | ឧភទេមហគ្ឃៈគន្ធី (តមក) .......... | ៤០១ |
| — — | ប្រវត្តិសាស្ត្រនៃស៊ីវិល្ហ៍ខ្មែរសម័យបុរាណ (តមក) | ៤០៦ |
| ក្រុមជំនុំវប្បធម៌ | ស័ព្ទបារាំងប្រែជាខ្មែរ ញ៉ុក-ថែម ស្រង់ (តមក) | ៤១២ |
| លោកសាង-សាភិត លេខានុការ | រឿងព្រែកភូមា (តមក) .......... | ៤១៧ |
| អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន | រឿងសាមកុក (តមក) .................. | ៤២៥ |
| — ទេពពិទូរ ឈឹម-ក្រសេម | ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) . . . | ៤៣៣ |
| ក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ | សារការវត្តវិហារទន្ទឹមលោកកែវ-ហង់តេង (តចប់) | ៤៤១ |
| **ផ្នែកសាសនា** | | |
| លោក ម៉ុញ-តាំត្រ៍ | ពុទ្ធសាសនា និងកាហ៊ិរសាសនា (តចប់) ... | ៤៤៧ |
| លោក ភិយ-ប៊ុក ក្រមការ | ពន្ធិមាស៊ុទ្វីប (តមក) .......... | ៤៥០ |
| ព្រះទេពសត្ថា ស៊ូរ-ហាយ | សប្បុរិសធម្មកថា (តចប់) .......... | ៤៥៦ |
| **កំណត់ទិនប្រវត្តិការណ៍** | | |
| ព្រះមហា កែ-អៀង | ពិធីដង្ហែព្រះសារីរិកធាតុ វត្តដំណាក់ សៀមរាប | ៤៦២ |
| ព្រះទេពសត្ថា ស៊ូរ-ហាយ | ពិធីបុណ្យស្រង់ទឹក សម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ .... | ៤៦៨ |
| ក្រសួងធម្មការ | បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី (តមក) .. | ៤៧៨ |


ឆ្នាំទី ២២ – លេខ ៦ ខែមិថុនា ឆ្នាំ ១៩៥០ – តំលៃជាវ ១ ឆ្នាំ ១៤៥ រៀល ។

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc Kramakar à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déba Sattha So-Hay membre de la Commission du Tripitaka

## TABLE DES MATIÈRES

### Partie littéraire :


| | | page |
|---|---|---|
| M. Ray-Buc Kramakar (I.B.) | Recueil des paroles de GANDHI (suite). | 401 |
| —id – | Histoire: Ancienne civilisation khmère par M. George COEDES (suite) ... | 406 |
| Commission Culturelle | Recueil des mots traduits fait par M. NHOK-THEM .............. | 412 |
| M. Sang-Savath, Ministère des Finances | Contes birmans (suite)............ | 417 |
| Neak Oknha Vibularaja-sena Nou-Kân | Histoire de SAMKOK (suite)..... | 425 |
| Neak Oknha Debabidûra Chhim-Krasem | Histoire du Royaume du Cambodge (suite)......................... | 433 |
| Commission des Mœurs et Coutumes | Notice historique de la pagode de Vihara-Tontim de Neak Oknha Keo-Hâng | 441 |


### Partie religieuse:


| | | |
|---|---|---|
| M. Menh-Nakry | Le bouddhisme et les autres religions (suite) ............................ | 447 |
| M. Ray-Buc Kramakar | Lumière de l'Asie (suite) ......... | 450 |
| Brah Debasattha So-Hay | Sappurisaddhammakatha (suite et fin). | 456 |


### Notes et chroniques


| | | |
|---|---|---|
| Préah Moha Ker-Oeun, | Compte rendu des fêtes et de la procession des reliques sacrées à la pagode de Damnak (Siemreap) ..... | 462 |
| Préah Débasatha So-Hay | Cérémonie d'aspersion d'eau lustrale de Samdach Préah Moha Sumedhatbipadi Chuon-Nath, Chef de Secte Mohanikay ........................ | 468 |
| Ministère des Cultes | Nomination des nouveaux Chau-Adhikar (suite) ................ . | 478 |


22e Année: No 6 Juin 1950 — Prix d'abonnement: 145$00 par an.

ឱវាទមហាត្មះគន្ធី

# លោកវ៉ាយ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ

ដកស្រង់ពីសារពត៌មាន ហ្សឺនអាំង (Jeune Inde)

(តមក)

---

៣០ — របបប្រជាធិបតេយ្យមិនមែនជាវត្ថុមានសភាពដូចគ្រឿងច័ក្រ ដែលគេអាចលៃលកដោយកែប្រែរូបភាពក្រៅនោះទេ របស់នេះត្រូវកែប្រែនាមធម៌ ។

របៀបវណ្ណៈ

(៨ - ១២ - ១៩២០)

៣១ — ខ្ញុំមិនបានគិតដល់របៀបនឹងកំឡាំងប្រពៃណីសកល ដែលគួរមានចំពោះរដ្ឋាភិបាលប្រជាធិបតេយ្យនោះទេ យើងត្រូវស្វែងរកសភាពសាមគ្គីមូលជាឯកច្ឆន្ទ ក្នុងវត្ថុដែលមានសភាពខុសគ្នា ។

អំណាចដែលនឹងគាំទ្រហើយរបនាអ្នកទុព្វលភាពឲ្យកាន់តែប្រសើរឡើង លុះត្រាតែអំណាចនោះជាស្នាដៃនៃវិចារណញ្ញាណ ដែលបួបផ្ដើមពីសំឡេងតូចស្ងាត់នៅក្នុងសន្ដានយើង អំណាចនោះត្រូវឡប់ទៅជាកិច្ចដ៏លាមកយ៉ាងក្រៃលែង ។

របៀបវណ្ណៈ

(៨ - ១២ - ១៩២០)

៣២ — សំដីមានសភាពជាផរុសវាទ នាំឲ្យគេដឹងថាជាបុគ្គលញាប់ញ័រ ហើយនាំឲ្យបច្ចាមិត្តសង្ស័យមិនយល់ច្បាស់លាស់នូវកិច្ចដែលខ្លួន

ប្រព្រឹត្ត, សេចក្ដីសន្ដោសដោយករុណាជាកូនសោសម្រាប់បើកនូវទ្វារដែលនាំទៅកាន់ជោគជ័យ ។

គួរណាស់ តបើសេចក្ដីស ត្ដាស
(១៨-៩-១៩២៦)

៣៣– ពួកបិសាចអាចធ្វើការសំរេចនូវផលប្រយោជន៍បាន លុះត្រាតែមានពួកបិសាចដូចគ្នាជួយឧបត្ថម្ភផង ករតែងបានផលនោះពីសភាពអន់ទន់ខ្សោយនៃធម្មជាតិយើង ដើម្បីនឹងសង្កត់សង្កិនយើងឲ្យនៅក្រោមអំណាចវា ។

ចាបនៃអ្នកផា (ស្ទូទ្រ:)
(១៩-១-១៩២១)

៣៤– ព្រលឹងប្រទេសឥណ្ឌាតយុទ្ធនឹងដែកថែប ប្រទេសព្រិតានិក (អង់គ្លេស) ។

១៥-១២-១៩២១

៣៥– មហាត្មៈគន្ធីទូនានចំពោះពួកពលរដ្ឋនៅខេត្រក្រៅ–បណ្ឌិតវាទដែលមហាត្មៈគន្ធីបានថ្លែងដោយសន្ទើបទៅនឹងប្រជាជន ក្នុងឱកាសដែលលោកអញ្ជើញទៅទស្សនាការនៅខេត្រអ៊ុដ (Audh) ។

ការដែលនឹងតាំងប្រទេសក្នុងឋានៈជាស្វ័យរាជ្យហើយនឹងកិច្ចការពារនូវអំពើអយុត្តិធម៌ ដែលយើងមិនអាចនឹងធ្វើទៅតាមបំណងបាន ព្រោះយើងមិនបានប្រតិបត្តិតាមវិធានការដូចមានខាងក្រោម :

ក) យើងមិនត្រូវធ្វើបាបកម្មប្រជារាស្ត្រ, យើងមិនត្រូវបៀតបៀនបុគ្គលទីងដំបង, យើងមិនត្រូវប្រើបេសុញ្ញវាទ ឬកំហែងគំរាមបុគ្គលណាមួយឡើយ ។

ខ) យើងមិនត្រូវចូលទៅលុកលុយបុទ្ធកុងតាណរិដ្ឋដាន ។

គ) យើងត្រូវប្រតិបត្តិការទៅនឹងបច្ចាមិត្តរបស់យើងដោយប្រើសេចក្ដីល្អ. មិនត្រូវប្រើវិធីកំហែងបង្ខំដោយទារុណកម្ម ឬធ្វើឲ្យគ្មានទឹកបរិភោគ ឬរាំងរាមិនឲ្យពួកជាងកាត់សក់ ឬអ្នកអ៊ុតខោអាវអាក់ខានធ្វើការរបស់ខ្លួន ។

ឃ) យើងមិនត្រូវកាន់ចិត្តថា មិនព្រមបង់ពន្ធដារជូនរដ្ឋាភិបាល ឬមិនព្រមបង់ថ្លៃឈ្នួលផ្ទះឲ្យម្ចាស់គេហដ្ឋានទេ ។

ង) ប្រសិនបើមានគេបំណងចង់បន្ទោសពួកសាម៉ីងដារ (Zamindars) យើងត្រូវយកសេចក្ដីនេះ ទៅជំរាបលោកបណ្ឌិតនេហ៌រុ ហើយត្រូវយើងប្រតិបត្តិតាមឱវាទរបស់លោក ។

ច) ត្រូវយល់ថា យើងចង់ឲ្យពួកសាម៉ីងដារត្រឡប់មកជាមិត្តមេត្រីនឹងយើងវិញ ។

ឆ) ក្នុងពេលនោះ យើងមិនត្រូវប្រទុស្តរាយនឹងរដ្ឋាភិបាល យើងត្រូវស្តាប់បង្គាប់រាជការគ្រប់ក្រសួង គ្រប់ក្រុម ។

ជ) យើងមិនត្រូវបញ្ឈប់អយស្ម័យយាន (រទេះភ្លើង) ធ្វើឲ្យខានដើរ ឬឡើងជិះអយស្ម័យយានគ្មានសំបុត្រទេ ។

ឈ) ប្រសិនបើចៅហ្វាយនាយយើងណាមួយត្រូវគេចាប់ឃុំឃាំង យើងមិនត្រូវប្រទុស្តរាយឃាត់ហាមមិនឲ្យគេចាប់ទេ ។ បុបង្កហេតុឲ្យមានចលាចលវឹកវរក្នុងទីនោះ បុព្វហេតុនៃរឿងនេះមិនអាចនឹងស្ងប់ស្ងាត់ទៅបាន ព្រោះរដ្ឋាភិបាលបានចាប់ចៅហ្វាយនាយៈយើងហើយ, តែហេតុនោះទៅជាពិតប្រាកដ បើក្នុងពេលនោះយើងវង្វេងស្មារតីទៅប្រព្រឹត្តទារុណកម្មវិញ ។

ញ) ត្រូវចៀសវាងកុំសេពសុរានឹងមេរ័យ កុំសេពសតិសមោសានុសថ (Stupéfiants) កុំប្រព្រឹត្តនូវអបាយមុខគ្រប់យ៉ាង ។

ដ) ត្រូវបំពេញករណីយកិច្ចចំពោះស្ត្រី ទុកស្ត្រីទាំងនោះដូចជាមាតាយើង ដូចជាបងប្អូនស្រីយើង, ត្រូវគោរពកោតខ្លាចស្ត្រីហើយការពារកុំឲ្យអ្នកណាប្រមាថ ។

ឋ) ត្រូវញ៉ាំងជាតិឥណ្ឌូនឹងមហាហ្គ័តឲ្យមានសាមគ្គីព្រមព្រៀងគ្នាកាន់តែមួនមាំឡើង ។

ឌ) យើងមិនត្រូវយល់ថា ជាតិឥណ្ឌូមានឋានៈផ្សេងគ្នាបុសំគាល់ថាមានជាតិឥណ្ឌូខ្ពស់ ជាតិទាបជាតិបុជាពួកស្ទ្រៈ អ្នកងារ (Intouchables) ត្រូវបណ្ដុះធម៌សមភាព បុភាតរភាព ឲ្យមានកង្សន្ដានចិត្តចំពោះប្រជាជាតិគ្រប់ជាន់-ថ្នាក់ទាំងអស់; យើងត្រូវគិតថា ប្រជារាស្ត្រឥណ្ឌូទាំងមូលជាបងប្រុសបងស្រីយើង ជាប្អូនប្រុសប្អូនស្រីយើង ។

ឃ) យើងមិនត្រូវលេងល្បែងស៊ីសងឬភ្នាល់គ្នា ។

ង) យើងមិនត្រូវប្រព្រឹត្តលួចប្លន់ ។

ច) យើងមិនត្រូវពោលពាក្យមុសារាល់ៗ បើទុកជាពាក្យនោះប្រកប ដោយវិចារណញ្ញាណយ៉ាងណាក៏ដោយ យើងត្រូវប្រព្រឹត្តធម៌សុចរិត ក្នុងការប្រស្រ័យគ្នាខាងពាណិជ្ជកម្ម ។

ឆ) យើងត្រូវនិយមប្រើរហាត់រវៃអំបោះនៅគ្រប់គេហដ្ឋានទាំងអស់ ហើយត្រូវតែប្រុសស្រីផ្ទៀតឱកាស ដើម្បីទីងរវៃកប្បាសឬបង្ហាត់ក្មេង ញុំាងចិត្តឲ្យឧស្សាហ៍រៀនត្បាញរវៃបួនម៉ោងក្នុងមួយថ្ងៃ ។

ជ) យើងមិនត្រូវនិយមប្រើសំពត់បរទេស ត្រូវនាំគ្នាប្រើប្រាស់តែ សំពត់ដែលជនជាតិយើងត្បាញដោយអំបោះរវៃខ្លួនឯង ។

ឈ) យើងត្រូវរកគ្នាឯងជាអាជ្ញាកណ្ដាល សម្រាប់ផ្សះផ្សាការរាំៗ ឈ្លោះទាស់ទែងគ្នា មិនត្រូវធ្វើពាក្យប្ដឹងទៅតុលាការទេ ។

ញ) កិច្ចសំខាន់បំផុតដែលយើងត្រូវចាំជាប់ក្នុងហឫទយវត្ថុជានិច្ច គឺ ត្រូវសង្កត់សង្កិន កុំឲ្យចិត្តខឹងទោមនស្សផ្ទុះក្នុងសន្ដានឡើងបាន, ហើយ មិនត្រូវប្រើទារុណកម្មក្នុងរឿងនេះ ព្រមទាំងត្រូវរងដោយហសនចិត្តនូវ អំពើកាចសាហាវដែលគេធ្វើរលោកមកលើយើង ។

**មនុស្សធម៌និងសភាពស្នេហាជាតិ**
**(៩ - ៣ - ១៩២១)**

**( មានត )**

## ប្រវត្តិសាស្ត្រនៃស៊ីវិល័យខ្មែរក្រុភណា

## លោកប៉ាយ-ប៊ុក ក្រមការ ប្រៀបរៀង

(៣២៨)

តាមសិលាចារឹកទាំងនោះ យើងអាចយល់បានអំពីបញ្ហាខាងសាសនានៃស៊ីវិល័យខ្មែរក្នុងសម័យនោះថា ព្រះមហាក្សត្រិយ៍ជាសាសនូបត្ថម្ភកៈ ជាអភិរក្សនូវប្រពៃណីសាសនាព្រមទាំងព្រះស្តូបចេតិយ ដែលពួកជនគជនបានបូជាថ្វាយចំពោះព្រះអង្គ, ព្រះមហាក្សត្រិយ៍ត្រូវធ្វើរាជពលិកម្មនឹងពិធីបុណ្យផ្សេងៗ តាមទំនៀមទម្លាប់ជូនទៅទេវតា ដើម្បីនឹងរក្សាសេចក្ដីសុខដល់ប្រជាជន, ត្រូវការពារកុំឲ្យបច្ចាមិត្តខាងក្រៅចូលមកលុកលុយក្នុងព្រះរាជអាណាចក្រ ត្រូវរក្សាសន្តិសុខខាងក្នុងប្រទេស ដោយត្រាស់បង្គាប់ឲ្យប្រជាជនប្រតិបត្តិតាមរបៀបស័ក្តិម គឺការបែងញែកទៅតាមពួកក្រុមក្នុងស័ក្តិម ។ គេមិនអាចដឹងបានដោយច្បាស់ប្រាកដថា តើព្រះមហាក្សត្រិយ៍ ជាមេកម្មសិទ្ធិលើដីក្នុងព្រះរាជអាណាចក្រទាំងមូលឬ ។ តែគេបានឃើញព្រះអង្គចែកដីទំនេរ ហើយទ្រង់បានប្រថាប់ព្រះសង្ហាលើលិខិតដែលផ្ទាស់ប្តូរអសង្ហារិមៈ ។

ប៉ុន្តែតាមសង្កេតឃើញៈ គេស្គាល់មិនច្បាស់លាស់នូវព្រះរាជចរិយានឹងបុគ្គលិកលក្ខណៈនៃព្រះមហាក្សត្រិយ៍ ២៥ អង្គ ដែលសោយរាជ្យសម័យអង្គរ ក្នុងរវាងសតវត្សទី ៩ ទៅសតវត្សទី ១៤ ។ មានតែព្រះ

មហាក្សត្រិយ៍អង្គមួយទេ ដែលគេអាចធ្វើនូវប្រវត្តិព្រមទាំងប្រមូលវត្ថុធាតុនៃជីវភាពព្រះអង្គបានគ្រប់យ៉ាង គឺព្រះបាទជ័យវរ្ម័នទី ៧ ដែលទ្រង់សោយរាជ្យរវាង ២០ ឆ្នាំ ខាងចុងសតវត្សទី ១២ ។ ព្រះមហាក្សត្រអង្គនេះទ្រង់មានថាមភាពខ្លាំងមហិមា ព្រះទ័យលោភលន់ពន់ប្រមាណ, ព្រះរូបចំឡាក់នឹងព្រះរូបនៅក្បាច់ជញ្ជាំងដែលគេបានឃើញជាក់ស្តែងថា ព្រះអង្គពិតមែនតែមានព្រះជន្មាយុរវាង ៥០ ឆ្នាំ តែមានព្រះកាយពលមាំមួននៅឡើយ, កាលនៅតរុណវ័យព្រះអង្គបានរងទុក្ខលំបាកជាច្រើនឆ្នាំ ទ្រង់ស្តេចទៅនៅក្នុងប្រទេសដទៃ ឃ្លាតចាកពីព្រះអគ្គជាយា ដែលទ្រង់សព្វព្រះរាជហឫទ័យជាខ្លាំង កាលព្រះអង្គវិលត្រឡប់មកកាន់ព្រះរាជនិវេសស្ថានវិញ បានទ្រង់តតាំងប្រាំងដណ្តើមរាជ្យពីស្តេច ១ អង្គដែលមានចរិយានាំឲ្យប្រទេសជាតិទៅកាន់សេចក្តីវិនាស ។ ព្រះបាទជ័យវរ្ម័នបានស្រោចស្រង់ប្រទេសកម្ពុជាពីសង្គ្រាមចាម ហើយបានចាត់ចែងរៀបចំប្រទេសឲ្យបានស្ថានដ៏ឧត្តមផុត ទ្រង់ជួសជុលព្រះរាជធានី, បានស្អាងប្រាសាទបាយ័ននឹងព្រះវិហារពុទ្ធសាសនាជាច្រើន, បានស្ថាបនាមន្ទីរព្យាបាលរោគចំនួន ១០២ ខ្នងនៅគ្រប់ខេត្តក្នុងព្រះរាជអាណាចក្រ ហើយនឹងសាលាសំណាក់តាមផ្លូវឆ្ងាយ ដែលជាផ្លូវគមនាគមន៍ទាក់ទងគ្នាទៅរកក្រុងធំៗក្នុងប្រទេស ។

បំពោះបុគ្គលិកលក្ខណៈនៃព្រះមហាក្សត្រិយ៍អតីតសម័យអង្គរ គេបានដឹងនូវរឿងរ៉ាវបន្តិចបន្តួចក្នុងរជ្ជកាលនោះអំពីអ្នកនិពន្ធក្នុងពេលនោះ ព្រោះពួកកវីនិពន្ធក្នុងជាន់នោះច្រើនតែងលើកដំកើងព្រះមហាក្សត្រិយ៍ជាទេពនិម្មិត, សេចក្ដីព្យាយាមនៃពួកកវីក្នុងសម័យនោះ គឺខំរចនាមហារាជទាំងនោះឲ្យមានសភាពសម្បើមអស្ចារ្យ ដោយសរសើរអំពីកិច្ចការដែលទ្រង់ធ្វើ អំពីព្រះរាជចរិយគុណធម៌ អំពីកិច្ចការស្នាព្រះហស្តគួរជាទីស្ញប់ស្ញែង, ទាល់តែព្រះមហាក្សត្រិយ៍ពេលនោះមានតេជានុភាពលើសពួកទេវតាដែលមានពណ៌នាក្នុងគម្ពីរឥណ្ឌៀនោះទៅទៀត ឧទាហរណ៍ដូចព្រះឥន្ទ្រ គឺជាព្រះមេឃនាទ (Tonnerre) និងជាព្រះវរុណ (pluie) ព្រះអង្គបានធ្វើពលិកម្មក្នុងសាស្ត្រតែមួយរយដង មាននាមសន្មតថ្វាយថា "ព្រះមួយរយពលិកម្ម" ។ ដើម្បីនឹងសរសើរថាព្រះមហាក្សត្រិយ៍មានព្រះទ័យជ្រះថ្លាក្នុងសាសនា ពួករាជកវីពោលថា "ព្រះអង្គទ្រង់បានធ្វើពលិកម្មមួយសែនដង, លើសព្រះឥន្ទ្រដែលបានធ្វើពលិកម្មតែមួយរយដង" ។ ឧទាហរណ៍មួយទៀត: ព្រះសិវៈបានទៅតាំងសីលនៅរមនីយដ្ឋានមួយ ក្នុងឱកាសដែលព្រះអង្គបានពិចារណានូវធម៌ ទទួលមាននីវរណធម៌គឺកាមច្ឆន្ទមកគ្របសង្កត់នាំឲ្យព្រះអង្គត្រេកត្រអាលក្នុងកាមរាគដោយតណ្ហា បានយកព្រួញមួយបាញ់ចំហទយវត្ថុ, ព្រះសិវៈទ្រង់ព្រះក្រោធជាខ្លាំង បានធ្វើឲ្យតណ្ហាទៅជាផេះដោយព្រះនេត្រសំឡឹងចំ ។

ដើម្បីនឹងសរសើរអំពីព្រហ្មចរិយធម៌នៃព្រះមហាក្សត្រិយ៍   ពួករាជនិពន្ធពោលថា " ព្រះសិវៈដែលមានជោគជ័យតែមួយផង   ដោយយកចក្ខុប្រសាទសំឡឹងតណ្ហា គួរខ្លាស់អស់ព្រះមហាក្សត្រិយ៍   ដែលឈ្នះតណ្ហាគ្រប់ពេលគ្រប់ខណៈ   ដោយព្រះអង្គបានផ្ចញ់ផ្ចាល់ចំពោះអារម្មណ៍ទាំងអស់ ។

ព្រះមហាក្សត្រិយ៍ជាព្រះអម្ចាស់ផែនដី, មានឋានន្តរខ្ពស់ជាងទេវតាឥន្ទព្រហ្ម, ព្រះអង្គនៅក្នុងព្រះរាជធានីៗ នេះ មិនមែនដូចសេចក្ដីយល់នៃពួកទេសចរ ដែលមិនពិនិត្យហ្មត់ចត់នោះទេ គឺជាព្រះរាជធានីមានកំពែងស្នាមៈភ្លោះនឹងព្រះវិហារមានរូបភាពជាចេតិយ   នៅចំពាក់កណ្ដាលក្រុងគឺជាចក្រវាឡតូច (Microcosme) ឬជារស្មីនៃចក្រវាឡធំ ដែលមានក្នុងគម្ពីរសាសនាឥណ្ឌូ (Cosmologie Hindoue) បានថ្លែង ។ សារៈសំខាន់នៃរាជាធិបតេយ្យ ដែលព្រះមហាក្សត្រិយ៍បានអប់រំជាធាតុមួយប្រកបដោយនិច្ចតាធម៌ ឬអមតធម៌របស់អាត្មននោះ គេបានប្រមូលយកទៅរចនាជារូបលិង្គមួយ   ជាបដិមាករដែលធ្លាក់ប្រសិទ្ធលិង្គព្រះសិវៈ  រូបសម្មតិនេះគេយកទៅដាក់ក្នុងព្រះវិហារដែលសាងចំពាក់កណ្ដាលក្រុងដែលគេស្មានថានៅចំពាក់កណ្ដាលលោក ។ លិង្គនេះគឺជាព្រះបរមនាមនៃព្រះដែលរក្សាស្វេតច្ឆ័ត្រ   (Dieu Roi ou dieu de la royauté)   ជាឯកនាមនៃព្រះមហាក្សត្រិយ៍នៅលើផែនដី   គឺជារស្មីឬកំសួលនៃព្រះនោះប៉ុណ្ណោះ

បានធ្លាក់ចុះពីលើមេឃ ដោយមានព្រាហ្មណ៍ម្នាក់នាំយកមកថ្វាយនៅលើភ្នំមួយបំពោះព្រះមហាកសត្រនៃសន្តតិវង្ស ។ ការសម្ពន្ធកិច្ចព្រះមហាក្សត្រិយ៍ នឹងពួកទេវតានៅលើភ្នំពិសិដ្ឋជាទីគោរព (Montagne Sacrée) ដោយមានព្រះសង្ឃជាប្រធាន នោះត្រូវធ្វើពិធីសព្វឆ្នាំនៅព្រះវិហារមានរូបភាពជាចេតិយដែលស្ថិតនៅចំពាក់កណ្ដាលក្រុង ដោយហេតុថាដូចជាភ្នំព្រះសុមេរុ ជាភ្នំដែលសន្មត់ពិភពលោកតាមជាតិឥណ្ឌូ នៅចំពាក់កណ្ដាលចក្រវាឡ ហើយកំពូលឡើងចូលទៅកប់មេឃ មានស្ថានភពតាំងពីអបាយភូមិជាន់ទាបឡើងទៅ ក៏នៅទីងបង្កើភ្នំនោះដែរយ៉ាងណាមិញ, បូជនិយដ្ឋានដែលតាំងនៅកណ្ដាលព្រះវិហារ ដែលនៅចំកណ្ដាលព្រះរាជធានី ជាទីសម្រាប់ធ្វើសម្ពន្ធកិច្ចនៃមនុស្សលោកទៅនឹងពពួកទេវតាឥន្ទព្រហ្ម ដោយមានព្រះមហាក្សត្រិយ៍ឬព្រះសង្ឃជាអ្នកបំពេញកិច្ចក្នុងពិធីនោះ ក៏យ៉ាងនេះឯង. ។

ព្រះមហាក្សត្រិយ៍នីមួយ ៗ អង្គណាដែលមានពេលទុកាសទំនេរបានប្រើមធ្យោបាយកសាងព្រះស្តូបចេតិយចំពាក់កណ្ដាលក្រុង ដល់ព្រះអង្គសោយព្រះទិវង្គតទៅ ព្រះអដ្ឋិនៃព្រះមហាក្សត្រិយ៍នោះគេត្រូវយកទៅបញ្ចុះនៅព្រះស្តូបនោះ ហើយមុននឹងសោយព្រះទិវង្គត ទ្រង់ត្រូវសម្មតិនាមមួយ ហើយប្រកាសថា ព្រះអង្គទ្រង់យាងទៅបដិសន្ធិនៅស្ថានណា ហើយព្រះវិញ្ញាណក្ខន្ធចូលទៅសន្ថិតក្នុងព្រះឬទេវតាណា ។

ការសោយរាជ្យតវង្ស ត្រូវបាតវិធីតាមរបៀបធម្មតា ចំពោះភេទបុរស តាមថ្នាក់ជាព្រះរាជបុត្រច្បង ; តែជួនកាលមានពិធីខុសពីរបៀបនេះដែរ ។ បើពិចារណាទៅតាមសន្តតិវង្ស ឃើញថាក្រសែខាងស្ត្រីច្រើនជាប់ទាក់ទងគ ។ គ្នាក្នុងព្រះរាជវង្សានុវង្ស : ធម្មតាព្រះរាជទាយាទគឺព្រះជេដ្ឋានៃព្រះភគិនី ដូចមានពណ៌នាក្នុងករណីនៃខត្តមត្រកូលខាងក្រោមនេះ ឬដូចក្នុងកុលសម្ពន្ធជាតិមួយ (Tribus mois) ក្នុងសម័យបច្ចុប្បន្ន ។ ពួកជាតិមួយប្រើសិទ្ធិមួយហៅថា មាតេយ្យកា (matriarcat) គឺសិទ្ធិខាងមាតាជាប្រធានក្នុងការសម្រេចកិច្ចការទាំងពួង ។ បើតាមសេចក្តីយល់ទូទៅ : ព្រះរាជទោហិន (Usurpateurs) ដែលនឹងធ្វើព្រះរាជ-សិទ្ធិឲ្យបានពេញលក្ខណ:តាមផ្លូវច្បាប់ ត្រូវធ្វើព្រះរាជសមរសជាមួយនឹងព្រះរាជបុត្រី ឬ ព្រះរាជទេយាសិត (une femme) នៃអតីតមហារាជ ។

នៅក្រោមបញ្ជាការនៃព្រះមហាក្សត្រ ព្រះរាជវង្សានុវង្ស នឹងមន្ត្រីធំ ។ ដែលមានវង្សត្រកូលខ្ពង់ខ្ពស់ ច្រើនជាអ្នកជាប់វង្សខាងមហារាជ ដែលរួបរួមហៅថា អភិជន សិទ្ធិជាអនាធិបតេយ្យ (Oligarchie Aristocratique) ដែលមានឋានន្តរស័ក្តិជាប់តវង្សត្រកូល ហើយមានមុខងារទៅតាមក្រសួងក្នុងប្រទេស ។

(មានត)

# សព្ទបារាំងប្រែជាខ្មែរ

## របស់គណៈកម្មការវប្បធម៌

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម រួបរួម

(តមក)

---

Démagogie = ប្រជាភិថុតិ (=ថុត) (ការបញ្ចើចប្រស្ដ)

Chambre de Commerce = មន្ទីរពាណិជ្ជកម្ម

Chambre mixte de Commerce et d'Agriculture = មន្ទីរចំរុះពាណិជ្ជកម្មនឹងកសិកម្ម ។

Primata = ប្រថមតា

Duplicata = ទុតិយតា

Triplicata = តតិយតា

Couloir = របៀង

Membre correspondant = សមាជិកឆ្លើយឆ្លង

Correspondance = ការឆ្លើយឆ្លង, លិខិតឆ្លើយឆ្លង

(Le 31-12-48)

Scepticisme = លទ្ធិមជ្ឈធាតុ

Optimisme = លទ្ធិសុទិដ្ឋិ

Pessimisme = លទ្ធិទុទិដ្ឋិ

Nécessaire = ខានពុំបាន

Sceptique = អ្នកមជ្ឈធាតុ

Optimiste = អ្នកសុទិដ្ឋិ

Pessimiste = អ្នកទុទិដ្ឋិ

(Le 4 1-49)

Patron de chaloupe breveté = នាយកប៉ាល់មានប្រកាសនីយប័ត្រ

Peintre = វិចិត្រករ

Préparateur diplômé = អ្នកផ្សំឱសថមានសញ្ញាប័ត្រ

Agents de vulgarisation agricole = ភ្នាក់ងារផ្សាយបំណេះកសិកម្ម (ដល់មហាជន)

Calculateur = អ្នកគិតលេខ

Copiste = អ្នកចម្លង

Correcteur = អ្នកកែតម្រូវ

Gestion = ការចាត់ចែង

Gardien chef d'aérodrome = មេឆ្មាំវាលយន្តហោះ

Gardien = ឆ្មាំ

Gardien de paix = (ប៉ូលិស) សន្តិបាល

Identification de bétail = អ្នកកត់ភិនសត្វ

Gérant = អ្នកចាត់ការ

Geste = កាយវិការ

Mouvement = ចលនា (ចៈ-ល៉ៈ-ណា)

Position = ឥរិយាបថ, ទីតាំង, ស្ថានភាព

Attitude = អាកប្បកិរិយា

Lecteur au son = អ្នកអានតាមសូរ

Ouvrier instructeur des écoles industrielles = កម្មករបង្រៀន សាលាឧស្សាហកម្ម

Identité = អត្តសញ្ញាណ

Titre d'identité = អត្តសញ្ញាណប័ណ្ណ (21-1-49)

Armurier = អាវុធិក

Caporaux-éclusiers = កាប៉ូរ៉ាល់ទំនប់ទឹក

Economiste = អ្នកសេដ្ឋកិច្ច

Ag nce de Représentation commerciale = ផ្ទះតំណាងហាងជំនួញនានា

Protection des intérêts des commerçants = ពាណិជ្ជឧបត្ថម្ភ

Calqueur = អ្នកផ្ទាប់ចម្លង

Caporaux matelots = កាប៉ូរ៉ាល់កម្មករនាវា

Chef d'entretien certifié = មេថែរក្សាមានវិញ្ញាបនប័ត្រ

Chef étalonnier = មេបង្កាត់សេះ

Résultat = ល័ទ្ធផល ( លា៉ត - ធ: - )

Compositeur et héliographe des T. P. = អ្នកផ្គុំនិងអ្នកសុរិយលេខនៃសាធារណការ ។

Planimétreur = អ្នកសមភូមិមាត្រ ( -- ស: ម:- )

Restituteur de Cadastre = អ្នកថតកែតម្រូវសុរិយោដី

Sapeur pompier = អ្នកលត់ភ្លើង

Teneur de carnet et croquisseur = អ្នកកាន់សៀវភៅនិងអ្នកគូររ៉ាស

Croquis = គំនូររ៉ាស

Garçon de laboratoire et manipulateur = អ្នកបំរើកន្លែងពិសោធន៍និងអ្នកលាយថ្នាំ

Lithographe et relieur = អ្នកសិលាលេខនិងអ្នកដេរសៀវភៅ

Maitre d'hôtel et chef-cuisinier = មេសណ្ឋាគារនិងមេចុងភៅ

Vaguemestre - planton = ពាក់ម៉ែស្ត្រនិងប៉ុងតុង

Agent de statistique local = ភ្នាក់ងារស្ថិតិស្រុកអាយ

Agent lecteur de marégraphe = ភ្នាក់ងារមើលកំរិតទឹកជោរ - នាច

Chaineur = អ្នកទាញខ្សែម៉ែត្រ

Etalonnier et traqueur = អ្នកបង្ហាត់សេះនឹងអ្នករឹតទឹកដោះ

Facteur tram = ហ្វាក់ទ័រជនបទ

Guichet = បញ្ជរ

Guichetier = បញ្ជរបាល

Plombier = ជាងសំណរ

Saigneur et racleur de l'abattoir = អ្នកពិឃាដនឹងអ្នកកោសក្នុងទីសត្តឃាដ

Désinfecteur = អ្នករម្ងាប់មេរោគ

(Le 4 – 2 – 49)

Source = ប្រភព

Dossier = សំណុំរឿង, សំណុំការ

Congé = ការឈប់លំហែ

Autorité = អំណាច

Prendre Congé = សុំលាចាក

Donner Congé = បញ្ឈប់

Centraliser = ផ្ដើមផ្ឈការ

(មានត)

# រឿងព្រេងភូមា

## លោក សាង-សារ៉ាត លេខានុការក្រសួងហិរញ្ញវត្ថុ

ប្រែពីភាសាបារាំងមកជាខ្មែរ

(តមក)

ក្នុងកាលដ៏កន្លងយូរណាស់មកហើយ នៅក្នុងប្រទេសតិក្កាថូ (Tekkatho) មានព្រះរាជបុត្រស្តេចមួយអង្គ ជាយុវអភិជន នឹងមានកូនប្រុសអ្នកក្រម្នាក់នៅក្នុងប្រទេសនោះដែរ ដែលបានរៀនសូត្រជាមួយគ្នាក្នុងព្រះវិហារមួយ ជាមួយនឹងនារីកូនរបស់បុរសម្នាក់ទៀត ដែលជាអ្នកមានភោគសម្បទយ៉ាងវិសេស ។

មានថ្ងៃមួយ នាងកំពុងចំឡងមេទន្ទេញ ដែលគ្រូនាងចារទុកលើស្លឹករិត ស្រាប់តែនាងធ្វើឲ្យធ្លាក់ដង្កៀបប្រាក់របស់នាង ហើយនាងទនតាមមើលទៅឃើញព្រះអង្គម្ចាស់នៅពីក្រោម នាងបានអង្វរព្រះអង្គម្ចាស់នោះសូមឲ្យរើសដង្កៀបប្រាក់នោះឲ្យនាង ។ ឯព្រះអង្គម្ចាស់នេះ កាលពីថ្ងៃមុន មានព្រះហឫទ័យស្រឡាញ់នាងជាពន់ពេក ប៉ុន្តែក្នុងឱកាសដ៏ប្រសើរនេះបែរជាទ្រង់ធ្វើកន្តើយវិញ, ទ្រង់គ្រាន់តែងើបមើលនាង ហើយមានព្រះរាជឱង្ការដោយញញឹមថា: "ខ្ញុំរើសដង្កៀបនេះជូននាងវិញបាន; ប៉ុន្តែខ្ញុំសុំធ្វើឱសន្យាថា ខ្ញុំស្រឡាញ់នាង សុំឲ្យ

នាងសន្យាថា ដល់កាលណានាងអញ្ជើញត្រឡប់ទៅផ្ទះរបស់ឪពុកម្ដាយនាងវិញ សុំនាងទៅរកខ្ញុំក្នុងទីផ្កាកំផ្លាំងសម្ដេចព្រះមាតាខ្ញុំ រួចនាងត្រូវបណ្ដោយទុកឲ្យខ្ញុំបេះបុប្ផាដ៏បរិសុទ្ធ គឺរូបរបស់នាងនេះកុំខាន" ។ នារីនោះលុះឮដូច្នោះ ក៏គិតមួយស្របក់ នាងឥតមានចិត្តស្រើបស្រាលស្នេហាអ្វីបន្តិចក្នុងព្រះអង្គម្ចាស់នេះសោះ តែនាងក៏បានព្រមព្រៀងសន្យាទៅ ទាំងមានសេចក្ដីខ្មាសអៀន ។ ឯព្រះអង្គម្ចាស់ក៏ទ្រង់ហុចដង្កៀបប្រាក់នោះឲ្យទៅនាងវិញ ; នាងទទួលយកហើយនិយាយឡើងថា : "សុំព្រះអង្គម្ចាស់ទ្រង់ជឿជាក់ចុះថា ខ្ញុំម្ចាស់នឹងធ្វើតាមកតិកាសញ្ញានេះមិនខាន" ។

លុះកាលណានាងរៀនចេះចប់សព្វគ្រប់ហើយ នាងក៏ត្រឡប់ទៅផ្ទះបិតាមាតាវិញ ។ ចំណែកខាងព្រះអង្គម្ចាស់ ស្ដេចទ្រង់យាងត្រឡប់ទៅប្រទេសរបស់ព្រះអង្គវិញដែរ ។ កាលទ្រង់យាងទៅដល់ប្រទេស មិនយូរប៉ុន្មាន សម្ដេចព្រះបិតារបស់ព្រះអង្គទ្រង់សោយព្រះទិវង្គតទៅ ហើយព្រះអង្គក៏បានឡើងសោយរាជ្យជាស្ដេចផែនដីស្នងព្រះបរមរាជបិតា ។

ហេតុតែស្ដេចផែនដីមានកិច្ចការនឹងអំណាចច្រើនពេក ព្រះអង្គទ្រង់ភ្លេចនាង ទាំងភ្លេចពាក្យសន្យាមុននោះបាត់ទៅ ។ ប៉ុន្តែចំណែកនាងឥតភ្លេចទេ ។ តាមទំនៀមទំលាប់ស្រុកនោះ ត្រូវឪពុកម្ដាយនៃបុត្រីរើស

រកប្ដីឲ្យកូនតាមចិត្ត, នាងក៏បានគោរពតាមរបៀបនេះ ឥតល្អៀងបន្តិចឡើយ ។ លុះដល់នាងរៀបមង្គលការរួច នាងស្រឡាញ់ប្ដីណាស់ ប៉ុន្តែដោយជាប់កិច្ចសន្យានឹងដៀសវាងពុំបាន នាងក៏អង្វរសុំច្បាប់ប្ដី ចំនួន ២-៣ ថ្ងៃ ហើយបានទាំងប្រាប់ប្ដីថា នាងទៅសងចំពាក់ពាក្យសន្យាមួយដែលនាងបានធ្វើកាលពីមុន ។ ឯប្ដីក៏បានសាកសួរនាងគ្រប់ប្រការ, នាងបាននិទានរឿងដែលកើតមានឡើង ក្នុងព្រះវិហារមួយនៅប្រទេសតិក្កាថូ ។ នាងនិយាយថា: "ខ្ញុំទៅទូលព្រះរាជាថា ខ្ញុំមានប្ដីហើយ រួចមុខជាទ្រង់នឹងបំភ្លេចកិច្ចសន្យានេះពុំខាន" ។

ឯស្វាមីនឹកក្នុងចិត្តថា "ពាក្យសន្យាជាបំណងមួយដ៏ឧត្ដមណាស់ មិនថាតែអ្នកកាន់ព្រះពុទ្ធសាសនា ឬអ្នកមិនកាន់ទេ សឹងតែផ្ដាច់ពាក្យសន្យានោះមិនបាន" ហើយក៏យល់ព្រមឲ្យភរិយាចេញទៅ ។ ស្វាមីកើតទុក្ខជាខ្លាំង ប៉ុន្តែមានចិត្តសង្ឃឹមជាក់ថា: ភរិយាមុខជាត្រឡប់មកវិញ ដោយឥតខូចខ្លួនប្រាណ ហើយនាងមុខជានៅស្រឡាញ់ខ្លួនដដែលមិនខាន ។ នាងឱនក្បាលទាល់តែដល់ចុងជើងរបស់ស្វាមី រួចនាងទៅស្អិតស្អាងខ្លួន ពាក់សុទ្ធតែមាសពេជ្រ នឹងសំលៀកបំពាក់ណាដែលនាងស្រឡាញ់ជាងគេបំផុត ។ លុះស្រេចកិច្ចតែងខ្លួនហើយ នាងក៏ចេញដំណើរទៅ មានទាំងស្រីស្នំម្នាក់ទៅជាមួយផង ។

---

លុះទៅដល់ពាក់កណ្ដាលផ្លូវ នាងជួបប្រទះនឹងមេចោរម្នាក់, មេចោរនេះ ចាប់ដៃនាងជាប់ ហើយនិយាយថា "អ្នកទៅណាមកណា? អ្នកមានកិច្ចការអ្វី? ម្ដេចក៏ដើរតែម្នាក់ឯងក្នុងផ្លូវស្ងាត់យ៉ាងនេះ? ចូរអ្នកដោះសំលៀកបំពាក់និងគ្រឿងមាសពេជ្រទាំងអស់នោះមកឲ្យយើងឲ្យឆាប់ ៗ ឡើង ប៉ុន្តែយើងឆ្ងល់ណាស់ តើអ្នកទៅណាបានជាតែងខ្លួនយ៉ាងដូច្នេះ?" ។ នាងឆ្លើយទៅវិញថា: "ឯសំលៀកបំពាក់និងគ្រឿងមាសពេជ្រទាំងអស់នេះ ជារបស់លោកហើយ ខ្ញុំមិនអាចការពារបានទេ ព្រោះខ្ញុំខ្សោយហើយខ្ញុំមកតែឯងផង ឯហេតុដែលខ្ញុំដើរមកនេះ ខ្ញុំមិនលាក់អ្វីនឹងលោកទេ" ។ រួចនាងដំណាលរឿងប្រាប់មេចោរនោះថា "កាលណោះ ខ្ញុំនៅរៀនសាលាក្នុងប្រទេសតិក្កាថ្ប ខ្ញុំសន្យានឹងព្រះអង្គម្ចាស់មួយព្រះអង្គថា ដល់ខ្ញុំត្រឡប់ពីរៀនទៅផ្ទះឪពុកម្ដាយខ្ញុំវិញ ខ្ញុំទៅជួបនឹងទ្រង់ បើសិនណាជាខ្ញុំមិនចាំពាក្យរបស់ខ្ញុំនេះទេ សុំកុំឲ្យខ្ញុំបានស្គាល់ស្ថានទេវតាឡើយ, ខ្ញុំបានសុំអនុញ្ញាតប្ដីរបស់ខ្ញុំ ដែលឪពុកម្ដាយខ្ញុំដាក់ទុកឲ្យ ឯប្ដីខ្ញុំក៏សុខចិត្ត រួចខ្ញុំធ្វើដំណើរមក ហើយស្រាប់តែមកជួបប្រទះនឹងលោកនេះ" ។ មេចោរលុះកាលណាបានឮដូច្នោះ ក៏មានចិត្តសរសើរជាខ្លាំងថា "នាងនេះបានកាន់សេចក្ដីពិតត្រង់ណាស់ ហេតុដូច្នេះអញមិនត្រូវដំទាស់ផ្លូវនាង" ហើយបើកឲ្យនាងធ្វើដំណើរតទៅមុខទៀត ដោយឥតយកអ្វីពីនាងបន្តិចសោះ ។ ប៉ុន្តែមេចោរនេះ បានផ្ដាំឲ្យនាងមក

រកខ្ទិកាលណា នាងត្រឡប់មកវិញ ។ ស្ត្រីនោះលុះបានរួចពីកណ្តាប់ដៃចោរដូច្នេះ នាងបានដើរទៅដល់ដើមពោធិធំមួយដើមដែលមានស្លឹកជាច្រើន ។ ដើមពោធិនេះ មានទេវតាមួយអង្គរក្សាគង់នៅលើមែកមួយធំ ។ ទេវតានេះ លើកដៃបញ្ឈប់នាង ហើយសួរថា "នាងទៅណា?" រួចគិតចុះមកដីដើម្បីចាប់នាង ។ នាងឆ្លើយថា: "ឱ មហាបពិត្រអើយ! ឯហេតុដែលបណ្តាលឲ្យខ្ញុំមកដល់លោកនេះគឺហេតុយ៉ាងនេះទេ" រួចនាងនិទានរឿងដែលនាងប្រាប់មេចោររួចមកហើយនោះ ។ ទេវតាមានចិត្តកោតសរសើរនាងជាច្រើន ហើយបានសុំឲ្យនាងមកជួបនឹងលោក កាលណានាងត្រឡប់មកវិញ រួចលោកក៏ឲ្យនាងធ្វើដំណើរតទៅទៀត ។

លុះនាងទៅដល់វាំងស្តេច, ទេវតាដែលរក្សាស្វេតច្ឆ័ត្របានបើកទ្វារចំហយ៉ាងធំឲ្យនាងចូល ដើម្បីជាកិច្ចគោរពដោយសារនាងកាន់ពាក្យសច្ចៈនេះ នាងបានទៅដល់ព្រះរាជាដោយឥតយឺតយូរឡើយ ។ ឯព្រះរាជាទ្រង់ភ្លេចនារីដ៏មានរូបល្អឆើតឆាយ ដែលមានពាក់គ្រឿងយ៉ាងប្រពៃនេះ ហើយដែលជាគូកនរបស់ព្រះអង្គពីដើម ។ ស្តេចទ្រង់សួរទៅនាងអំពីបំណងរបស់នាងដែលមកនេះ ។ នាងឆ្លើយដោយអឹមអៀមថា: "សូមទ្រង់ព្រះមេត្តាប្រោស! ខ្ញុំម្ចាស់នេះហើយដែលបានសន្យានឹងព្រះអង្គកាលដែលព្រះអង្គនៅរៀនជាមួយខ្ញុំម្ចាស់ នៅព្រះវិហារមួយក្នុងប្រទេសតិក្កាថូ; កាលដែលខ្ញុំម្ចាស់ត្រឡប់មកដល់ផ្ទះវិញ ឪពុក

ម្ដាយរបស់ខ្ញុំម្ចាស់ បានរៀបចំទុកដាក់ឲ្យខ្ញុំម្ចាស់មានប្ដី រួចខ្ញុំម្ចាស់បានសុំច្បាប់ស្វាមីមករកព្រះអង្គ ដើម្បីបំពេញកិច្ចដែលបានសន្យានោះ" ។ ព្រះរាជាទ្រង់មានព្រះបន្ទូលទៅកាន់នាម៉ឺនសព្វមុខមន្ត្រីថា "នេះបានចំជាប្រសើរមែន ស្ត្រីនេះបង្ហាញឲ្យឃើញជាក់ស្ដែងថានាងមិនក្បត់ពាក្យសំដីរបស់នាង គួរឲ្យស្ងើចណាស់" រួចព្រះអង្គទ្រង់ព្រះរាជទានរបស់ល្អៗ ផ្សេងៗ ឲ្យនាង មានកងកធ្វើអំពីពេជ្រយ៉ាងល្អិតនឹងចិញ្ចៀនដ៏ថ្លៃថ្លាជាដើម ហើយទ្រង់ត្រាស់បញ្ជារលេងថា "ខ្ញុំឲ្យរបស់អស់នេះទៅនាង ដោយសារនាងមានចិត្តត្រង់ល្អ ចូរនាងត្រឡប់ទៅវិញឲ្យបានជួបជុំជាមួយស្វាមីរបស់នាងចុះ, ឯពាក្យដែលយើងបានសន្យានោះ នឹងផុតរលត់ពីថ្ងៃនេះហើយ, សេចក្ដីកោតសរសើររបស់ខ្ញុំមានស្មើសេចក្ដីគោរពដល់រូបនាងដែរ" ។

លុះនាងទទួលគ្រឿងមាសពេជ្ររួចស្រេចហើយ នាងមានចិត្តរីករាយជាពន់ពេក ហើយនាងត្រឡប់មកផ្ទះវិញ មានទាំងទាហាននាំទាល់តែដល់មាត់ទ្វារភូមិរបស់នាង ។ នាងដើរទៅដល់ដើមពោធិធំហើយនិយាយបន្ទន់សំឡេងដ៏ពីរោះដូចសំឡេងនៃសត្វករវិក (Karaviek) ថា "លោកសំរាន ឬលោកភ្ញាក់? ខ្ញុំបានបំពេញកិច្ចសន្យារបស់ខ្ញុំជាមួយព្រះករុណារួចស្រេចហើយ · ឥឡូវខ្ញុំត្រឡប់ទៅផ្ទះឪពុកម្ដាយរបស់ខ្ញុំវិញ ប៉ុន្តែខ្ញុំបានសន្យានឹងលោកថា កាលណាខ្ញុំត្រឡប់មកវិញ ខ្ញុំចូលមក

រកលោក" ។ កាលពេលនោះ ទេវតាបានឮសំឡេងនាងក៏ចុះពីលើមែកពោធិ៍ខ្ពស់មកដល់ហើយក៏កោតសរសើរនាងជាអនេក ប៉ុន្តែលោកនិយាយថា: "ការណ៍នេះជាការណ៍លំបាកនឹងនិយាយណាស់ ព្រោះគេឲ្យនាងផុតទុក្ខអាសន្នរួចទៅហើយ ម្តេចឡើយក៏នាងចូលចិត្តមករងទុក្ខអាសន្ននេះវិញ?" ។ នាងនិយាយថា: "មែនហើយលោក ប៉ុន្តែបើខ្ញុំខ្លាចអាសន្ននេះឬខ្លាចស្លាប់ខ្ញុំមិនមករកវិញនោះ ដល់ថ្ងៃក្រោយទៅ ខ្ញុំនឹងធ្លាក់ខ្លួនកងរណ្តៅទុក្ខទាំង ៤ មិនខាន ដោយសារខ្ញុំមិនចាំពាក្យរបស់ខ្ញុំនេះ, កាលបើដូច្នេះ ខ្ញុំមិនអាចចូលកងកតទេវលោកបានឡើយ" ។

ឯទេវតាដែលមានតណ្ហាកំពុងតែផុតពេលយ៉ាងខ្លាំងនោះ លុះបានឮនាងនិយាយយ៉ាងនេះហើយ ក៏បាត់ចិត្តលែងចង់ប្រាថ្នារូបកាយដ៏ល្អរបស់នាង បែរទៅជាមានសន្តិចរិយាដ៏ប្រសើរវិញ ហើយយកដើងពានមាសមួយដែលមានលំអដោយក្បាច់របនាផ្សេង ៗ ឲ្យទៅនាង ដើម្បីជារង្វាន់ដល់ចិត្តស្មោះត្រង់របស់នាង ហើយបានឲ្យពរស័ព្ទសាធុការឲ្យនាងរស់នៅបានសុខសប្បាយយឺនយូរឆ្នាំផង រួចឡើងទៅលើមែកពោធិវិញ ហើយលើកដៃជាសញ្ញាឲ្យនាងធ្វើដំណើរតទៅមុខទៀត ។

ស្ត្រីនោះលុះចេញអំពីទីស្ថានទេវតានេះទៅ នាងដើរកាត់តំរង់ទៅដល់កន្លែងមេចោរ ។ ពេលនោះ មេចោរកំពុងដេកលក់យ៉ាងស៊ប់ ។

នាងនិយាយថា: "ខ្ញុំមករកលោកដើម្បីលាងពាក្យសន្យារបស់ខ្ញុំ ឯជីវិតខ្ញុំព្រមទាំងមាសពេជ្រទាំងអស់នេះ សឹងនៅក្នុងកណ្ដាប់ដៃរបស់លោកហើយ" ។ មេចោរស្រែកឡើងថា: "នេះបានចំជាចំឡែកមែន ខ្ញុំភ្លេចបាត់ហើយ, ណ្ហើយអ្នក! អ្នកបានកាន់ពាក្យសន្យាដ៏លំបាកពិតមែន, អំពើយ៉ាងនេះរកគ្មានទេក្នុងលោកនេះ, ហេតុដូច្នេះ បើសិនណាខ្ញុំធ្វើបាបអ្នក ខ្ញុំប្រាកដជាមានទុក្ខមិនខាន សូមអ្នកអញ្ជើញចេញពីទីនេះដោយសួស្ដីចុះ! សូមទេវតាតាមរក្សាអ្នកកុំបីឃ្លាតឡើយ!" ថាហើយមេចោរក៏បើកឲ្យនាងទៅ រួចឈរមើលនាងទាល់តែដាច់កន្ទុយភ្នែក ថែមទាំងមានចិត្តកោតសរសើរនាងជាខ្លាំង ។

ក្នុងរវាងប៉ុន្មានថ្ងៃក្រោយមក នាងបានទៅដល់ផ្ទះស្វាមីរបស់នាងដោយឥតមានរឿងហេតុអ្វីឡើយ ។ ឯស្វាមីនាងដែលទន្ទឹងចាំមើលផ្លូវរាល់វេលានោះ លុះបានឃើញនាងត្រឡប់មកវិញដោយគ្មានខូចខាតប្រាណ នឹងគ្មានគ្រោះថ្នាក់យ៉ាងនេះ ក៏មានចិត្តត្រេកអរសើចញញឹមញញែមមិនដាច់ ។ លុះកាលណា បានស្ដាប់រឿងដ៏ប្លែក ដែលនាងនិយាយប្រាប់ដោយគ្មានលាក់លៀមត្រង់ណាសោះ បុរសស្វាមីបានសរសើរនាងជាច្រើន ហើយបាននាំនាងទៅផ្ទះបិតាមាតារបស់នាង ។ ក្រោយមកស្វាមីភរិយារស់នៅដោយសុខសប្បាយជាមួយគ្នាទៅហោង ។

(មាឌត)

# រឿងសាមកុក

## កណ្ឌទី ៦

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តទៅ)

សម័យនោះ ការរាជការក្នុងស្រុកគីជីវ ជាកម្មសិទ្ធិស្រេចដាច់ខាតលើអួនសៀវទាំងអស់ ។ ហានហុកឃើញដូច្នោះក៏ភ្ញាក់ខ្លួនថា "អួនសៀវមកធ្វើដូច្នេះក៏ព្រោះតែអញគិតខុស ដែលអញនឹងនៅស្រុកនេះជាមួយនឹងអួនសៀវនោះ អំណើះតទៅមុខឃើញនឹងកើតអន្តរាយពុំខាន", លុះគិតដូច្នោះ ក៏កាត់ចិត្តបោលករិយាបុត្រ រត់តែម្នាក់ឯងទៅនៅស្រុកតាន់លីវ ។

ឯកង់ស៊ុនចានកាលបានដឹងថា អួនសៀវបានស្រុកគីជីវហើយ ក៏ឲ្យកង់ស៊ុនអួតជាប្អូនទៅសួរអួនសៀវថា តើនឹងព្រមបែងទ្រព្យរបស់មនុស្សប្រុសស្រីទឹកដីក្នុងស្រុកគីជីវពាក់កណ្ដាល តាមសំបុត្រសញ្ញាធ្វើទុកនោះឬទេ? ។ អួនសៀវតបថា ឲ្យទៅអញ្ជើញកង់ស៊ុនចានជាបងអ្នកមកចុះនឹងនិយាយគ្នា ។ កង់ស៊ុនអួតក៏លាត្រឡប់ទៅវិញ បានពាក់កណ្ដាលផ្លូវ ស្រាប់តែជួបនឹងកងទ័ពលើកផ្ទុច់មកទាំងសង់ខាងហើយស្រែកថា "អញជាទាហានមហាឧបរាជ," ថាហើយក៏លើកធ្នូបាញ់ត្រូវកង់ស៊ុនអួតស្លាប់នៅទីនោះ; បណ្ដាទាហានកង់ស៊ុនអួតដែលមកជាមួយក៏រត់រួចទៅដល់ស្រុកហើយយកសេចក្ដីទៅជំរាបកង់ស៊ុនចានតាមការណ៍ ។

កង់ស៊ិនចានខឹងខ្លាំងណាស់ក៏ថា វេលានេះអួនសៀវមានភ័ព្វត្រឡប់បាន ស្រុកគីជីវដោយស្រួលហើយ ហេតុម្តេចគេចប្រើកលឧបាយឲ្យទាហាន មកចាំបង្កប់សម្លាប់កង់ស៊ិនអួតប្អូនអញទៀត ហើយក្លែងថាជាទាហាន តាំងតុ: អួនសៀវធ្វើដូច្នេះមុខគួរឲ្យស្តាយណាស់ បើអញសងសឹក អួនសៀវមិនបានទេ ខ្លួនអញមិនពេញជាកូនប្រុសជាតិជាទាហាន ឡើយ ៗ តមក កង់ស៊ិនចានក៏រៀបចាត់ចែងទាហានកេណ្ឌមកអស់ពី ក្នុងស្រុក លើកទៅច្បាំងនឹងអួនសៀវ ។

ឯអួនសៀវដឹងការណ៍ថាកង់ស៊ិនចានលើកទាហានមកដល់ព្រំខែត្រ ហើយក៏កេណ្ឌទាហានលើកជាក្បួនទ័ពចេញទៅទទួលនៅមាត់ស្ទឹងក្លួនហូ ត្រើយខាងលិច ស្ទឹងនោះមានស្ពានថ្មសិលាឆ្លងរហូតទៅ ៗ កង់ស៊ិន ចានឃើញទ័ពអួនសៀវលើកមក ក៏ជិះសេះឆ្លងស្ពានទៅហើយស្រែក ហៅអួនសៀវថា ខ្លួនឯងនេះបំជាមនុស្សទុច្ចរិតគិតមកល្បួងបញ្ឆោតអញ យកប្រយោជន៍ខ្លួន ហើយថែមធ្វើឧបាយកលសម្លាប់ប្អូនអញទៀត ៗ អួនសៀវឮដូច្នោះក៏ឡើងជិះសេះបរឆ្លងស្ពានទៅ ប្រទល់មុខនឹងកង់ស៊ិន ចានហើយឆ្លើយថា ហានហ៊ុកជាមនុស្សឆោតល្ងង់មិនដឹងគិតអ្វីសោះ លើកស្រុកគីជីវឲ្យយើងទាំងអស់ជាស្រេចហើយ ត្រូវការអ្វីអ្នកឯងមក លាដៃទាមយកចំណែកទទេដូច្នេះមិនគួរឡើយ ៗ កង់ស៊ុនចានតបថា ចៅហ្វាយខែត្រទាំងអស់ប្រឹក្សាមូលមាត់គ្នា ព្រោះឃើញថាឯងជាមនុស្ស

សុចរិតពិតត្រង់ ទើបតាំងឲ្យធ្វើជាមេទ័ពធំដូច្នេះ ឥឡូវអញឃើញចិត្តគំនិតឯងប្រហែលគ្នានឹងសត្វតិរច្ឆាន មិនគួរមកនៅក្នុងស្ថាន មនុស្សលោកឲ្យបង្អៀតទេ ។ អួនសៀវខឹងណាស់ក៏សួរទាហានថា នរណានឹងយកអាសាចាប់កង់ស៊ុនចានមកឲ្យយើងបាន ។ ប៊ុនទិវឆ្លើយសុំខ្លួនហើយកំខ្លួនជិះសេះឆ្លងស្ពានទៅ, កង់ស៊ុនចានក៏ញាក់សេះថយទៅឈរដល់ផែនដី, ប៊ុនទិវក៏បរសេះតាមទៅចូលប្រយុទ្ធគ្នាបាន ៩ ឬ ១០ ស្ទៀត, កង់ស៊ុនចានកំឡាំងខ្សោយក៏ថយសេះទៅបំបាំងនឹងពួកទាហាន, ប៊ុនទិវក៏ដេញបំពានទៅទៀត ទាហានទប់ពុំឈ្នះក៏ប្រាសបែកបាក់ខ្ចាត់ខ្ចាយអស់, នៅមានទាហានកង់ស៊ុនចាន ៤ នាក់ទៀត បំផាយសេះចូលមកតយុទ្ធនឹងប៊ុនទិវ ៗ ចាក់នឹងលំពែងត្រូវទាហានម្នាក់ធ្លាក់ពីលើសេះស្លាប់, ទាហាន ៣ នាក់ញាក់សេះរត់ថយចេញ, ប៊ុនទិវដេញតាមទៅទៀត ជិតទាន់កង់ស៊ុនចាន ក៏លើកលំពែងប្រុងនឹងចាក់, កង់ស៊ុនចានកន្ត្រាក់សេះបំផាយរត់ទំលាយកាត់ព្រៃទៅច្រើនតំបន់, ប៊ុនទិវក៏តាមប្រកិតពីក្រោយហើយស្រែកថា អាឯងចុះពីលើសេះឲ្យឆាប់ អញនឹងចាប់យកទាំងរស់ បើខំរត់ដោះ អញនឹងចាក់ឲ្យស្លាប់ឥឡូវ ៗ កង់ស៊ុនចានក៏បំផាយសេះទៅទៀត ឯធនូនឹងអាវុធក៏របូតធ្លាក់ពីដៃ មួកក៏ធ្លាក់ពីលើក្បាល លុះរត់ទៅដល់ដើមក្ទូមួយកន្លែង សេះក៏ជំពប់នឹងដុំថ្មដួលចុះ, ប៊ុនទិវលើកលំពែងនឹងចាក់ ទទួលមានទាហានម្នាក់ឈ្មោះជូឡុង ជិះសេះបរស្ទុះមកស្ទាក់

ពីមុខប៊ុនទិវជាប់ តាំងតែប្រកាប់តគ្នានឹងប៊ុនទិវ, ឯកង់ស៊ុនបានក៏ស្ទុះរត់រួចទៅពួននៅកៀនភ្នំនោះ, ដូឡុងនឹងប៊ុនទិវតយុទ្ធគ្នាដល់ ៦០ ស្នៀត មិនចាញ់មិនឈ្នះ ។ វេលានោះមានពួកទាហានកង់ស៊ុនបានដែលបែកទ័ពត្រឡប់លើកគ្នាមកទាន់ ក៏ចូលទៅឡោមព័ទ្ធប៊ុនទិវនៅក្នុងចំណោម, ប៊ុនទិវឃើញថានឹងចាញ់ប្រៀបគេ ក៏ញាក់សេះទំលុះទំលាយរត់ចេញទៅបាន ។ កង់ស៊ុនបានក៏ចេញមកពីកៀនភ្នំឃើញទាហាននោះមាឌធំខ្ពស់ប្រហែល ៦ ហត្ថ មុខមាត់សំបើមចិញ្ចើមក្រាស់ភ្នែកក្រឡោតក៏សួរថា អ្នកឈ្មោះអ្វី? បានមកជួយជីវិតយើងពេលនេះ យើងមានសេចក្ដីអរគុណជាច្រើន ។ ដូឡុងបន្ទន់ខ្លួនឱនគំនាប់ហើយថា ខ្ញុំបាទឈ្មោះដូឡុងសែតៀវ នៅស្រុកសៀងសាន់ ពីមុននោះខ្ញុំបាទទៅនៅនឹងអួនស៊ៀវម្ដង តែខ្ញុំបានឃើញថាអួនសៀវជាមនុស្សកំណាចអាក្រក់ណាស់ មិនជាមនុស្សសុចរិតទៀងត្រង់ទេ ខ្ញុំក៏រត់មកដោយបំណងទីពឹងនៅនឹងលោក ទទួលខ្ញុំបាទចេញមកជូនជាជួបនឹងលោកនៅទីនេះ ។ កង់ស៊ុនបានក៏មានសេចក្ដីត្រេកអរណាស់ ទើបឡើងជិះសេះមួយម្នាក់ ហើយនាំដូឡុងនឹងទាហានទាំងពួងលើកត្រឡប់ទៅបន្ទាយត្រើយស៊ួង ។

ឯអួនសៀវដល់ដឹងដំណឹងថា កង់ស៊ុនបានវិលទៅចូលបន្ទាយហើយ ឲ្យកំចាត់ហ៊ាន់លៀង, ប៊ុនទិវឲ្យលើកទាហានជ្មាក់មួយពាន់ បំបែកជា ២ ផ្លូវ ទៅបង្កប់នៅដើមស្ពាន បានសន្មតគ្នាថា " បើត្រូវសំឡេងផាវជា

សញ្ញាហើយ ឲ្យបាញ់ចម្រុះទាំងធ្នូស្នាតំរង់ទៅបន្ទាយ" ហើយចាត់ឲ្យចុកឃីលើកទាហានធ្នូ ៨០០ នឹងទាហានឡេវមួយម៉ឺនប្រាំពាន់ ជាកងមុខចេញច្បាំងបញ្ឆោត, ឯអ្នួនសៀវលើកទាហានប្រាំម៉ឺនជាទ័ពហួង លុះចាត់ស្រេចការហើយក៏ឲ្យទាហានទាំងអស់សម្ងំនៅស្ងៀម ។

ខណៈនោះ កងស៊ុនបានចាត់ឲ្យយ៉ាំកុងលើកទាហានជាកងមុខហើយបំបែកជាប៉ែកធ្នូស្នាំ តែដូឡុងនោះ កងស៊ុនបានពុំទាន់ស្គាល់ចិត្ត ក៏ចាត់ឲ្យលើកទាហានជាកងក្រោយ ហើយឲ្យយកទង់សរសេរជាតួអក្សរដោតឡើង អក្សរនោះថា "ឈួយគី" ប្រែថា "ទង់សម្រាប់មេទ័ព" ហើយលើកទាហានតាំងជាក្បួនទ័ពនៅលើស្ពានសិលានោះស្រេចហើយឲ្យទាហានទាំងពួងវាយឃោះវាយគងទូងគីរី ហោកញ្ច្រៀវអឹងកងតាំងពីព្រឹកដល់ថ្ងៃរសៀល, ទាហានក្នុងកងទ័ពអ្នួនសៀវក៏នៅសម្ងំស្ងៀម, ឯយ៉ាំកុងជានាយកងទ័ពមុខក៏លើកទាហានទន្ទ្រានចូលទៅ ។

ខាងទ័ពអ្នួនសៀវគឺចុកឃីជានាយកងទ័ពមុខ បានលើកទាហានថយបញ្ឆោតទៅផុតចុងស្ពាន ឃើញបានការហើយ ក៏អុជផាវជាសញ្ញាឡើងឯពួកទាហានធ្នូ ៨០០ នាក់បាញ់ចំរុះតម្រង់មក ។ យ៉ាំកុងយល់ថានឹងទ្រាំទ្រតទល់ពុំបានក៏ដេញទាហានថយក្រោយទៅដល់ដើមស្ពានវិញ ។ ចុកឃីឃើញបានការ ក៏បំផាយសេះកាន់ដាវចូលតយុទ្ធនឹងយ៉ាំកុងបាន ៥ ស្នៀត ហើយយកដាវកាប់យ៉ាំកុងធ្លាក់ពីលើសេះស្លាប់, ទ័ពកងស៊ុនបានប៉ែកធ្នូធ្នូនឹងស្នាក៏លើកគ្នាចូលព្រួតទាំងសងខាងមកទៀត ។

ខណៈនោះ ង៉ាន់លៀងនឹងប៊ុនទិវ ក៏លើកទាហានឆ្វេងស្តាំដែលបង្កប់នៅដើមស្ពាននោះបាញ់ធ្នូបម្រុះពីក្រោយ ទាហានកងស៊ុនចានចូលជួយពុំបាន បុកឃីក៏ដេញទាហានចូលប្រកាប់សង្ខុញទៅដល់កងស៊ុនចាន ហើយយកក្របីកាប់ដងទង់ជ័យបាក់ធ្លាក់ចុះ កងស៊ុនចានទប់ពុំឈ្នះ ក៏ត្រឡប់ថយទ័ពចុះពីស្ពានរត់ទៅ បុកឃីដេញជិតប្រកិតចាក់កាប់សម្លាប់ទាហានកងស៊ុនចានជាប្រឡំបល់ ទាហានដែលនៅសល់ទាំងប៉ុន្មានក៏រត់បែកបាក់ខ្ចាត់ខ្ចាយអស់ទៅ ។

ពេលនោះជូឡុងជានាយទ័ពក្រោយ ឃើញទ័ពមុខនឹងទ័ពហ្លួងបែក ក៏បំផាយសេះដែកចូលទៅតទល់នឹងបុកឃីបាន ៥ ស្នៀត, ជូឡុងយកទួនចាក់បុកឃីធ្លាក់ពីសេះស្លាប់ ថែមចូលដេញកាប់សេនាទាហាបុកឃីវក់វីកណ្តាលហ្វូងទ័ព ជូឡុងងាកទៅកាប់ខាងឆ្វេងៗក៏បែក ងាកទៅកាប់ខាងស្តាំៗក៏បាក់ នឹងរកអ្នកឯណាតទល់ពុំបាន, កងស៊ុនចានបានឃើញដូច្នោះក៏លើកទ័ពត្រឡប់មកជួយជូឡុង កងទ័ពបុកឃីក៏បែកអស់ទៅ ។

កាលបុកឃីកាប់ដងទង់សម្រាប់មេទ័ពបាក់ កងស៊ុនចានបែកទ័ពត្រឡប់ទៅក្រោយនោះ, មានទាហានម្នាក់ទៅប្រាប់អួនសៀវថា កងទ័ពបុកឃីបែកហើយ ។ អួនសៀវត្រេកអរណាស់ ក៏នាំតៀនហងនឹងទាហានកាន់ទួនប្រមាណ ៣០០ កាន់ធ្នូ ៥០ ចេញមកសំឡឹងមើលក្រៅបន្ទាយ

ឃើញសមដូចពាក្យទាហាននិយាយ អ្នកសៀវក៏ទះដៃសើចហើយថា កង់ស៊ុនបាននោះជាមនុស្សមិនចំណានក្នុងការសង្គ្រាមសោះ យើងគ្រាន់តែច្បាំងប៉ុណ្ណេះបែកទ័ពទៅហើយ ។ អ្នកសៀវក៏មានសេចក្ដីប្រមាទធ្វេសការ ។

ក្រោយនោះដូឡុងនឹងកង់ស៊ុនបាន ស្រែកលើកទាហានឆ្លងស្ពានតាមទៅទៀត លុះឃើញពួកទាហានអ្នកសៀវ ដូឡុងក៏បរសេះស្ទុះតាមទៅចាក់កាប់សម្លាប់ទាហានទាំងនោះពិការជាច្រើន ឯកង់ស៊ុនបានក៏ស្រែកលើកទាហានព័ទ្ធស្ទាក់ជុំវិញទ័ពអ្នកសៀវ ហើយបាញ់ធ្នូចម្រុះទៅទៀត ។

គៀនហង់ឃើញដូច្នោះភ័យណាស់និយាយនឹងអ្នកសៀវថា គ្រានេះយើងមុខជាខូចការនឹងសត្រូវហើយ លោកចូរអែបទៅខាងក្បែរបន្ទាយរត់ទៅចុះ ។ អ្នកសៀវតបថា "កើតមកជាជាតិទាហានហើយមិនត្រូវខ្លាចស្លាប់ទេ", ថាហើយក៏ស្រែកហៅទាហានឲ្យចូលច្បាំងប្រកាប់ជាប់គ្នា ពួកទាហានទាំងសងខាងក៏ប្រពាក់ប្រពូនទៅវិញទៅមក ។ ឆាំន់លៀង ឃើញកង់ស៊ុនបាននឹងដូឡុងច្បាំងជាប់ដៃគ្នានឹងទាហានខាងខ្លួន ក៏ដេញបញ្ចូនទាហានវាយព័ទ្ធខ្ទប់ពីខាងក្រោយថែមទៅទៀត ។ ទាហានអ្នកសៀវដែលលើកទៅបញ្ឆោតហើយបែកទៅនោះ លុះក្រឡេកឃើញទ័ពកំពុងប្រកាប់ជាប់ដៃគ្នា ក៏ពមកព្រួតខ្ទប់ពីខាងម្ខាង ។ ដូឡុងច្បាំងទល់ក្នុងកងទ័ពដែលខ្ទប់ជុំវិញ ឃើញថានឹងការពារពុំឈ្នះ

ទំលាយចេញចូលស្ពានរូចទៅ ។ អ្នកសៀវនឹងឆាន់លៀង ក៏លើកទាហានទន្ទ្រានតាមទាល់តែផុតស្ពាន បានចាក់កាប់សម្លាប់កងទ័ពកងស៊ុនចានធ្លាក់ពីលើស្ពានស្លាប់ជាច្រើន ហើយដេញកងស៊ុនចាននឹងជូឡុងហួសស្ពានទៅទៀត ប្រហែលចំងាយផ្លូវ៩០សិន ។

វេលានោះ ឡេវពីដឹងដំណឹង ទើបនាំកួនអ៊ូ តៀវហ៊ុយ នឹងទាហានទាំងពួងលើកមកជួយកងស៊ុនចាន កាលគ្រាឡេកឃើញទ័ពអ្នកសៀវលើកដេញកងស៊ុនចានបានទៅដល់ដើងភ្នំ, ឡេវពី កួនអ៊ូ តៀវហ៊ុយ នាំគ្នាបំផាយសេះស្ទុះទៅស្ទាក់ពីមុខសេះអ្នកសៀវៗ គ្រាឡេកឃើញឡេវពី កួនអ៊ូ តៀវហ៊ុយ នៅទទឹងពីមុខ ក៏តក់ស្លុតស្មើរនឹងបាត់ស្មារតី ដាវដែលកាន់នៅដៃក៏របូតធ្លាក់អស់នៅតែខ្លួនទទេ ហើយបែរត្រឡប់សេះស្ទុះថយក្រោយទៅចូលបន្ទាយ ។

ឯកងស៊ុនចានបានឃើញឡេវពី កួនអ៊ូ តៀវហ៊ុយ មកជួយដូច្នោះ ក៏មានសេចក្ដីសោមនស្សពន់ពេក សាកសួរគ្នាហើយក៏ថយចូលទៅកងបន្ទាយ ។ កងស៊ុនចានបាននិយាយប្រាប់ឡេវពីថា កាលគ្រាប៊ុនទីវជាទាហានអ្នកសៀវដេញខ្ញុំមក កុំតែបានជូឡុងចេញមកជួយ ខ្ញុំក៏មិនបានគង់ជីវិតទេ ពេលនេះអ្នកសៀវដេញខ្ញុំមកម្ដងទៀត បើកុំតែបានអ្នកមកជួយខ្ញុំៗ ក៏អន្តរាយជីវិតប្រាកដណាស់ ។

# ព្រះរាជពង្សាវតារក្រុងកម្ពុជា

ភាគទី ២

## សម័យអង្គរធំ

ឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តមក)

## ព្រះបាទជយវរ្ម័នទី ៥

ព.ស. ១៥១១-១៥៤៤, គ.ស. ៩៦៨-១០០១

កាលព្រះបាទរាជេន្ទ្រវរ្ម័នទី ២ សោយទិវង្គតហើយ, ព្រះជយវរ្ម័នរាជឱរស បានឡើងសោយរាជសម្បត្តិនៅក្រុងយសោធរបុរៈតមក ទ្រង់ព្រះនាម **ព្រះបាទជ័យវរ្ម័ន** រាប់ជាទី ៥ ។ ទ្រង់មានព្រះអគ្គមហេសីព្រះនាម **ឥន្ទ្រលក្ស្មី** មានព្រះរាជឱរស ១ អង្គព្រះនាម **ទិវាករ** ។

**ការផែនដី** — ក្នុងរជ្ជកាលនេះ ការគ្រប់គ្រងព្រះរាជអាណាចក្រទាំងមូលនៅគង់ដូចដើម ៗ ក្នុងផ្លូវរដ្ឋប្បសាសនោបាយ ព្រះបាទជយ-វរ្ម័នទ្រង់មានការសម្ពន្ធទាក់ទងទៅនឹងព្រះមហាក្សត្រិយ៍ផ្សេងៗ ដែលមានព្រះរាជអាណាចក្រនៅតាមផ្លូវទន្លេគង្គាក្នុងដែនឥណ្ឌា ជាច្រើនប្រទេស, ទ្រង់បានយកព្រាហ្មណ៍ប្រាជ្ញម្នាក់អំពីក្រុង ឌេលហី មកជាទីប្រឹក្សាការផ្សេងៗ ហើយទ្រង់ព្រះមេត្តាប្រោសព្រះរាជទាន នូវព្រះកនិដ្ឋភគិនី (មិនប្រាកដព្រះនាម) ឲ្យជាភរិយាព្រាហ្មណ៍នេះផង ។

**ការសាសនា** – ព្រះបាទជ័យវរ្ម័នទ្រង់និយមរាប់អានទាំងសាសនាព្រាហ្មណ៍ ទាំងព្រះពុទ្ធសាសនា ៗ ផ្នែកសាសនាព្រាហ្មណ៍ ព្រះអង្គបានរាជបុរោហិតឈ្មោះ **សិវកៃវល្យ** ដែលជាប់អំបូរវង្សអំពីរាជបុរោហិតក្នុងរដ្ឋកាលមុនៗ នឹងរាជបុរោហិតថ្មីដែលមកពីក្រុងឌេលហ៊ី ជាទីប្រឹក្សាការ នឹងធ្វើពិធីផ្សេងៗថ្វាយ ៗ ផ្នែកព្រះពុទ្ធសាសនា ព្រះអង្គបានសេនាបតី ១ នាក់ឈ្មោះ **វ្រិទ្ធិបណ្ឌិត** (ព្រិទ្ធបណ្ឌិត) សឹងជាអ្នកប្រាជ្ញមួយជាទីប្រឹក្សានឹងជាអ្នកចាត់ការផ្សេងៗក្នុងផ្នែកនេះ ៗ

**ការសាងវត្តស្ថាន** – តាមដែលបានស្រាវជ្រាវក្នុងវេលានេះប្រាកដថា ព្រះបាទជ័យវរ្ម័នអង្គនេះ ទ្រង់បានសាងប្រាសាទសិលា ដែលហៅថា ប្រាសាទព្រះវិ៍ន នៅក្នុងស្រុកកំពង់ស្វាយ (គឺនៅក្នុងទីរួមខេត្តកំពង់ធំក្នុងបច្ចុប្បន្ននេះ) ប្រាសាទនេះគង់រូបរាងនៅជាពស្តុតាងដរាបដល់សព្វថ្ងៃនេះ ៗ ក្រៅពីនេះ ព្រះឃ្លាំង (គឺប្រាសាទឃ្លាំង) ខាងជើងនឹងប្រាសាទកែវ (ដែលពាក្យសាមញ្ញហៅថា ប្រាសាទតាកែវ) នៅខាងកើតទៀបព្រះមហានគរ ក៏ប្រាកដថា សាងឡើងក្នុងរាជ្យសម័យនេះដែរ, ទាំងបានទ្រង់សាងវត្តព្រះឥន្ទ្រកោសី នៅក្នុងតំបន់សៀមរាបសព្វថ្ងៃនេះ ៗ

ព្រះបាទជ័យវរ្ម័នទី៥ស្តេចស្ថិតនៅក្នុងរាជសម្បត្តិបាន ៣៣ ឆ្នាំក៏សោយទិវង្គត ៗ រាជបណ្ឌិតថ្វាយព្រះនាមព្រះបរមសពថា **បរមវីរលោក** ៗ

ពួកព្រះរាជវង្សដែលបានសោយរាជ្យតៗមកអំពីព្រះបាទឥន្ទ្រវរ្ម័ន ទី ១ នៅក្រុងហរិហរាល័យ បានផុតវង្សត្រឹមព្រះបាទជយវរ្ម័នទី ៥ នេះ តអំពីនេះទៅ ជាវង្សដទៃ ។

## ព្រះបាទឧទយាទិត្យវរ្ម័នទី ១

**ព. ស. ១៥៤៤ - ១៥៤៥, គ. ស. ១០០១ - ១០០២**

កាលព្រះបាទជយវរ្ម័នទី ៥ សោយទិវង្គតហើយ, បើតាមច្បាប់រាជ-សន្តតិវង្ស រាជសម្បត្តិក្នុងវេលានោះ ត្រូវបានទៅព្រះ **ទិវាករ** ជារាជនុរសជេដ្ឋាយាទរបស់ព្រះបាទជយវរ្ម័នទី ៥, តែនេះមិនបានប្រព្រឹត្តទៅតាមគន្លងច្បាប់ទម្លាប់ទេ ដោយវេលានោះមានព្រះរាជវង្ស ១ អង្គ ព្រះនាម **ឧទយាទិត្យវរ្ម័ន** ជានុរសទី ២ របស់ព្រះរាជបតិវរ្ម័ន ជាក្សត្រិយ៍ចុងវង្ស បានតាំងខ្លួនជាគូបដិបក្ខនឹងព្រះទិវាករដើម្បីរាជសម្បត្តិ ហើយបានលបលើកទ័ពទៅរំលាងព្រះទិវាករចេញ ក្នុងពេលដែលទ្រង់នឹងឡើងគ្រងរាជបល្ល័ង្ក ហើយខ្លួនក៏ឡើងគ្រងរាជបល្ល័ង្កជំនួស មានព្រះបរមនាមថា **ព្រះបាទឧទយាទិត្យវរ្ម័ន** រាប់ជាទី ១ ។

ជាធម្មតា តែកាលណាមានការណ៍ចះបោរក្នុងប្រទេស កាលនោះតែងមាននានាប្រទេសដែលនៅជិតខាងចៀងក្អែកមើល ។

គ្រានោះ ក្សត្រិយ៍ឧបរាជមន អ្នកគ្រប់គ្រងនគរលំភូន, ព្រះនាម **ត្រាពក ឬ អត្រាពក** បានលើកទ័ពមកវាយនគរលវបុរៈ (លពរ)

របស់ខ្មែរ ដែលមានព្រះមហាឧបរាជព្រះនាម **ឧបិ្ឋតបក្រវត្តិ** ឬហៅខ្លីថា **បក្រវត្តិ** ជាអ្នកគ្រប់គ្រង ។ ព្រះបក្រវត្តិបានលើកទ័ពចេញតស៊ូនឹងបច្ចាមិត្រពេញទំហឹង តែតាមដែលអ្នកថ្កកការពិនិត្យទៅឃើញថា ព្រះបក្រវត្តិមិនអាចនឹងទប់ទល់កំឡាំងបច្ចាមិត្របាន, វេលានោះ ខាងក្រុងធំក៏មិនឃើញលើកទ័ពទៅជួយ ប្រហែលជាខាងក្រុងធំនោះមិនទាន់សាន្តត្រាណរៀបរយនៅឡើយ ។ ព្រះបាទឧទយាទិត្យវរ្ម័នគោងប្រយ័ត្នការផ្ដាល់ព្រះអង្គជាមមាញឹក ទើបមិនបានលើកទ័ពទៅជួយ ឬមួយមិនបានជ្រាបហេតុការណ៍នេះទេ ក៏សឹងតែថាបាន ។

ទុកជាក័ព្វធំ ទោះបីខាងក្រុងធំមិនបានអំពល់ផងក៏ដោយ តែជោគជាតារបស់លវបុរៈមិនទាន់ដល់កម្រិតរលត់ ដំណឹងនេះក៏ជួតជ្រាបទៅដល់ព្រះសូរ្យវរ្ម័ន មហាឧបរាជអ្នកគ្រប់គ្រងរដ្ឋមាល័យ (មាលយូ) ដែលមានស្រុកស្រែចម្ការនគរជារាជធានី ទ្រង់មិនមើលបំណាំក្នុងរឿងនេះ បានស្ដេចម្នីម្នាលើកទ័ពមកជួយព្រះបក្រវត្តិដោយរួសរាន់ ។ កងទ័ពខ្មែរទាំងពីរពួក បានព្រួតគ្នាវាយកងទ័ពព្រះអត្រាពកទាល់តែបរាជ័យ យ៉ាងខ្ទេចខ្ទីហើយតាមវាយរហូតដល់នគរលំភូន ទាល់តែបាននគរលំភូនមកជាសម្បត្តិរបស់ខ្មែរ, តែក្នុងវេលានោះនគរលំភូនគោងចំហសិន ព្រះសូរ្យវរ្ម័នទ្រង់មិនទាន់បានតាំងអ្នករាជការខ្មែរឲ្យទៅគ្រប់គ្រងនៅឡើយទេ ព្រោះទ្រង់មានព្រះរាជភារៈធំនៅក្នុងព្រះមហានគរ គោងស្ដេចប្រញាប់លើកទ័ព

ត្រឡប់ទៅក្រុងលវបុរៈវិញ ដើម្បីទឹងគិតការរម្ងាប់អសន្តិសុខ នៅព្រះមហានគរតទៅទៀត ។

ការណ៍ដែលព្រះឧទយាទិត្យវរ្ម័ន ក្បត់ដណ្តើមរាជសម្បត្តិ ដល់ទៅរំលាងព្រះទិវាករចេញនោះ លោកទុកជាអធម្មកម្ម ។ • អំពើអធម្មកម្មនេះ ទោះបីដូចម្តេចក៏ដោយគង់មិនជាទីគាប់ព្រះហឫទ័យនៃព្រះរាជវង្សធំ ៗ ដែលមានព្រះជន្មនៅក្នុងវេលានោះ, មិនត្រឹមតែព្រះរាជវង្សទេ សូម្បីប្រជារាស្ត្រ ៨ ក្នុងភាគ ១០ ក៏យល់ទាស់ដែរ, ដូច្នេះ ការគ្រងរាជបល្ល័ង្ករបស់ព្រះបាទឧទយាទិត្យវរ្ម័ន នៅក្នុងរាជ្យដែលត្រូវពិភាក្សាដោយផ្លូវច្បាប់តទៅ ។

ព្រះសូរ្យវរ្ម័ន ដែលស្តេចមកគង់នៅក្រុងលវបុរៈទាំងគ្រឿងចំបាំងនោះ ដើម្បីពិភាក្សាទឹងស្តាប់សំឡេងមហាជនក្នុងរឿងនេះ ។ កាលទ្រង់ព្រះសណ្តាប់សេចក្តីជំនុំរបស់ក្រុមជំនុំ ទឹងសំឡេងរាស្ត្រភាគច្រើនថា "មិនព្រមទទួលស្គាល់ ព្រះបាទឧទយាទិត្យវរ្ម័នហើយ ព្រះអង្គក៏លើកទ័ពសំដៅទៅក្រុងយសោធរបុរៈភ្លាម ដោយទ្រង់ព្រះចិន្តាឃើញថា ដែលទឹងរកសេចក្តីសុចរិតយុត្តិធម៌ឲ្យឃើញឡើងវិញ លុះតែប្រើកម្លាំងអាវុធ ។

ចំណែកខាងព្រះបាទឧទយាទិត្យវរ្ម័ន ទ្រង់ជ្រាបក្នុងព្រះអង្គមកហើយថា ការសោយរាជ្យរបស់ព្រះអង្គនោះ មិនបានប្រព្រឹត្តទៅដោយសុភាព ឬដោយច្បាប់ទម្លាប់ទេ ដូច្នេះត្រូវតែត្រៀមការទុកការពារព្រះ

អង្គជា យ៉ាងម៉ឺងម៉ាត់បំផុតជាដរាប ។ កាលទ្រង់ជ្រាបថា ព្រះសូរ្យវរ្ម័ន លើកទ័ពមកប្រទុស្តព្រះអង្គហើយ ក៏ត្រាស់ឲ្យសេនាបតីរៀបទ័ពចេញ តទល់មួយរំពេច ទាំងព្រះអង្គក៏ស្តេចចេញច្បាំងដោយព្រះអង្គឯងផង ។ កងទ័ពទាំងពីរខាងតស៊ូគ្នា យ៉ាងពេញសមត្ថភាព, តែក្នុងរយៈវេលាមិន យូរប៉ុន្មាន ខាងកងទ័ពព្រះសូរ្យវរ្ម័នក៏បានជ័យជំនះយ៉ាងដាច់ខាត ដោយ បានទាំងរំលាងព្រះជន្មជីព ព្រះបាទឧទយាទិត្យវរ្ម័នឲ្យសូន្យទៅផង ។

ព្រះបាទឧទយាទិត្យវរ្ម័នទី ១ ទ្រង់គង់នៅក្នុងរាជសម្បត្តិមិនលើសពី ១ ឆ្នាំ ទ្រង់ក៏សោយទិវង្គតក្នុងសមរភូមិ ។

ដោយហេតុដែលទ្រង់សោយរាជ្យដោយអយុត្តិធម៌នោះ បានជាកាល ទ្រង់សោយទិវង្គតទៅហើយ គេមិនបានថ្វាយព្រះនាមព្រះបរមសព ដូចព្រះបរមសពនៃព្រះមហាក្សត្រិយ៍ទាំងពួងទេ តែគេរាប់ជារដ្ឋកាល ១ ក្នុងព្រះរាជពង្សាវតារដែរ ព្រោះក្សត្រិយ៍អ្នកជារដ្ឋទាយាទគឺព្រះទិវាករ នោះផុតរលត់ទៅហើយ ប្រសិនបើអ្នករដ្ឋទាយាទនៅគង់ជីវិត ហើយ នៅតក្នុងវៀងរាជសម្បត្តិនោះ, ព្រះឧទយាទិត្យវរ្ម័ន ទោះបីច្បាំងឈ្នះ ដោយកំឡាំងអាវុធ បានឡើងសោយរាជ្យក៏ដោយ ក៏មិនត្រូវរាប់ជាព្រះ រាជាម្ចាស់ផែនដីពេញទីទេ ។

រាជសម្បត្តិតពីនោះ ក៏បានទៅព្រះសូរ្យវរ្ម័នអ្នកមានព្រះកិត្តិយស ខ្ពស់ និង មានព្រះសមត្ថភាពដូចពោលហើយ ។

## ព្រះបាទសូរ្យវរ្ម័នទី ១

ព.ស. ១៥៤៥ - ១៥៩៣, គ.ស. ១០០២ - ១០៥០

ព្រះសូរ្យវរ្ម័នអង្គនេះ ជាព្រះឱរសរបស់ព្រះមហាឧបរាជអ្នកគ្រប់គ្រងរដ្ឋមាល័យ ( មាលយូ ) ដ៏ជាបច្ចន្តរដ្ឋ ១ របស់កម្ពុជាក្នុងសម័យនោះ សិងតាំងរាជធានីនៅស្រីធម្មនគរ ។ ឯព្រះនាមព្រះរាជបិតានោះដូចម្ដេចមិនប្រាកដ, ប្រាកដតែថា ជាប់ជាព្រះញាតិមកអំពីព្រះនាង **ប្រិទ្ធិវិន្ទ្រទេវី** ដ៏ជាព្រះរាជជននីនៃព្រះបាទឥន្ទ្រវរ្ម័នទី ១ ។ ព្រះរាជមាតាព្រះនាមដូចម្ដេច ក៏មិនប្រាកដដែរ ។ កាលនៅកុមារទ្រង់បានទទួលសិក្សាបំណេះវិជ្ជាទាំងផ្លូវគតិលោកទាំងផ្លូវគតិធម៌ដោយបរិបូណ៌ គឺទ្រង់ចេះភាសាជ្វា - មាលយូ - ភាសាឥណ្ឌា - និងភាសាសំស្ក្រឹត ទ្រង់ជំនាញក្នុងក្បួនអក្សរសាស្ត្រ ទាល់តែប្រាកដព្រះកិត្តិយសថា **ក្សត្រប្រាជ្ញក្នុងក្បួនកាព្យ** ។ វេលាក្រោយមកព្រះអង្គបានទ្រង់និពន្ធកាព្យ ជាភាសាសំស្ក្រឹតជាច្រើន, កាព្យដែលទ្រង់និពន្ធនោះបានផ្សាយរហូតទៅដល់មហាប្រទេសឥណ្ឌា ដោយចំពោះគឺផ្សាយទៅដល់ប្រទេសអយុធ្យានឹងកាណោជ, ព្រះមហាក្សត្រនឹងអ្នកប្រាជ្ញក្នុងប្រទេសអំបាលនេះបានទត – អានហើយ ក៏និយមនឹងសរសើរទៀត ។ ទ្រង់បានសិក្សាវិជ្ជាគ្រប់គ្រងមានយុទ្ធសាស្ត្រជាដើមតាមរាជប្រវេណី ទ្រង់ជំនាញក្នុង

ក្បួនយុទ្ធវិធី រាប់ថាយ៉ាងឯក ១ អង្គ ។ កាលព្រះរាជបិតាទិវង្គតហើយ ព្រះអង្គក៏បានទទួលគ្រប់គ្រងរដ្ឋមាល័យស្នងព្រះរាជបិតាតមក ។

លុះមកដល់ឆ្នាំ ព.ស. ១៥៤៤ ក្រោយដែលព្រះបាទជយវរ្ម័នទី ៥ សោយទិវង្គតហើយ ក៏កើតសឹកទាំងក្នុងប្រទេសទាំងខាងក្រៅប្រទេស ចូលមកញាំញីថែមទៀត, ព្រះសូរ្យវរ្ម័នមហាឧបរាជ ទ្រង់ស្ដេចលើកកងទ័ពចេញរម្ងាប់អសន្តិសុខទាំងពីរផ្លូវឲ្យរាបទាបទៅ ដូចពោលហើយ ។ អំពីនោះមក ព្រះអង្គបានឡើងគ្រងពិភពកម្ពុជាទាំងមូល តែពុំទាន់បានធ្វើព្រះរាជពិធីបរមរាជាភិសេកនៅឡើយ ព្រោះហេតុក្នុងគ្រានោះ មានការណ៍បះបោរជាថ្មីទៀត ដោយមានព្រះរាជវង្ស ១ អង្គទៀត ព្រះនាម **ជ័យវីរវរ្ម័ន** តែមិនដឹងជាត្រកូលវង្សមកពីខាងណា បានបង្កហេតុជ្រែករាជ្យឡើងទៀត ។ ព្រះបាទសូរ្យវរ្ម័នទ្រង់ទ្រង់ចាត់ការក្រមាបព្រះជ័យវីរវរ្ម័ននេះផង ទ្រង់ចាត់ការផែនដីផ្នែកផ្សេងៗផង ដរាបដល់ឆ្នាំទី ៣ រឿងបះបោរទើបបានស្ងប់, ព្រះអង្គទើបត្រាស់ឲ្យធ្វើព្រះរាជពិធីបរមរាជាភិសេក។ រាជបណ្ឌិតថ្វាយព្រះបរមនាមតាមព្រះនាមដើមថា **ព្រះបាទសូរ្យវរ្ម័ន** រាប់ជាទី ១ ។ ព្រះអង្គមានព្រះអគ្គមហេសីព្រះនាម **វីរលក្ស្មី**[1] ។

---

១ មានព្រះអនុជ ២ អង្គ ព្រះធម្ម សទាសិវៈ ១ ជយោត្រូវ័ន ១ ។

(មានត)

សាវតារវត្តវិហារចក្ខុម
នៅឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម

ឧកញ៉ាកែវ - ហង់
ចាងហ្វាងរ៉ៃត្រត នៅឃុំ - ស្រុក - ខេត្តនេះ រៀបរៀង

( រង្វាន់លេខ ១ )

( ត — បប់ )

# ៤ — និយាយអំពីនាគជះក្តារនិងគ្រុឌ

នាគដែលដាក់នៅចែងចុងជង្ក្តារ លើដំបូលវិហារនោះ ខ្ញុំមិនដែលឮថាមានក្បួនច្បាប់ទេ ។ ដាន់ដើម វិហារនេះធ្វើដូចកុដិកឹងគ្មាននាគដីក, ខាងស្រុកបាត់ដំបង់ហៅ ប៉ូប ជាកេងខុះបោសថ, តមកធ្វើដំបូលស្របដូចផ្ទះខ្មែរ តែគ្មាននាគដែរ; ដាន់ដើម ច្រើនធ្វើជាសកុណាកន្ទុយហង្សដូចគល់កណ្តៀវ ដាក់នៅចុងជង្ក្តារជ្រុងចែង ច្រើនជារូបក្បាលតោ - ខ្លា ។ តមកប្រហែលជាជាងឬអ្នកកសាងយល់ថាក្បាលនាគល្អមើលហើយសមផង ។ តែរូបនាគនេះ ឮចាស់ៗ ថា នាគសៀម ហៅថា នាគសទ្ទឹក គ្មានក្អែកគ្មានម៉ាត់ទេ (ដែលបានឃើញហើយឮពាក្យចាស់ថានាគសៀម ជាង ៦០ ឆ្នាំហើយ) ។ តាមខ្ញុំយល់ឃើញប្រហែលខាងសៀមបង្កើតធ្វើរូបនាគដាក់វិហារជាមុនមែន ទើបផ្សាយមក

ស្រុកខ្មែរជាក្រោយ ៗ តមកជាអ្នកឆ្លាក់ក្បាលនាគធ្វើមានភ្នែកមាន មាត់មានធ្មេញមានចង្កូម មាត់ពាំកែវ មានពុកចង្កា រចនាប្លែកថែមឡើង ទៀត រហូតដល់សព្វថ្ងៃមើលឥតទាស់ភ្នែក; ប្រហែលយល់ថាកាលព្រះ ជាម្ចាស់បានត្រាស់ហើយ បានគង់លើនាគសំដែងធម៌ នាគជកពពារ បាំងពីលើមិនឲ្យព្រះអង្គត្រូវកំដៅព្រះអាទិត្យ ដូច្នេះទេដឹង? ព្រោះមាន ពាក្យចាស់ថា ធ្វើវិហារហើយ ត្រូវលើកដីរាជង្គារ មិនឮថាមាននាគ ណោះ ៗ ជាន់ដើម ពិធីលើកដីរាជង្គារនេះជាកិច្ចធំបំផុត អ្នកកសាង វិហារត្រូវក្រាបបង្គំទូលព្រះមហាក្សត្រ ទឹងសម្ដេចព្រះមហាសង្ឃរាជ; ព្រះមហាក្សត្រចាត់តំណាង, ព្រះមហាសង្ឃរាជយាងមកផ្ទាល់ ទើបអ្នក សាងលើកដីរាជង្គារនោះបាន ៗ របៀបលើកដីរាជង្គារ មានរបៀបពិ-ការដូចលើកវិហារ, សែនដីរាឡើងទៅមានកួស់បាំង តែដីរាមួយត្រូវលើក មុន មានរាយស្គារ គង ហោ៊ អុជផៅ ជាឱឡារិក ៗ ខ្ញុំធ្លាប់បានឃើញ បានដឹងកាលពីក្មេងមក មិនឮថានាគណោះ ៗ ធៀបបន្តិច ដូចប្រាសាទ អង្គរវត្ត ខ្ញុំមិនឃើញមានរូបនាគដាក់លើកំពូលប្រាសាទទេ ឃើញរូប នាគដាក់នៅតែត្រង់បង្កាន់ដៃ ៗ

## ៥– និយាយពីគ្រុឌនៅខាងក្រោម នាគនៅខាងលើ

រូបគ្រុឌនឹងនាគនេះ មិនមែនជាប្រស្នានៃបូរាណចារ្យទេ ប្រហែល

ជាជាងឬអ្នកកសាងចូលចិត្តធ្វើរូបគ្រុឌដាក់នៅជ្រុងថែង ៗ ខ្លះដាក់គ្រប់សសររបៀងវិហារទាំងអស់ ៗ ពីមុនមក ធ្វើតែក្បាច់អែក៉ ដាក់ជ្រុងថែងនឹងគ្រប់សសររបៀងទាំងអស់ ៗ

រូបគ្រុឌនាគនៅលើក្រោមនេះ បើប្រស្នាសម័យបច្ចុប្បន្នប្រហែលជាត្រូវដឹង! ៗ គ្រុឌជាអ្នកមានរិទ្ធិ នាគខ្លាចគ្រុឌ ឥឡូវនាគនៅពីលើគ្រុឌ ៗ ពួនជ្រកនៅថែងរបៀងសំយាបវិហារបែបខ្លាចនាគទៅវិញឬគ្រុឌពួនចាំចាប់នាគវិញទេដឹង! ៗ ប្រស្នាត្រង់នេះ ស្រេចនៅលោកជាអ្នកប្រាជ្ញពិចារណាផងចុះ ៗ

## ៦ – និយាយអំពីប្រយោជន៍កសាងវត្ត

អ្នកកសាងវត្តចង់បានប្រយោជន៍ធំបំផុត វត្តជាអន្ទ្រស្រុកជាសិរីសួស្តីភូមិស្រុកនៃអ្នកកសាង, បើវត្តចម្រើនរុងរឿង ភូមិស្រុកបំណុះវត្តក៏ចម្រើនមានភោគសម្បទ, បើវត្តអាប់ឪន ភូមិស្រុកក៏អាប់ឪនរិចរិលខ្សត់ខ្សោយទ្រព្យធនធាន ៗ ពាក្យនេះខ្ញុំបាទព្របាស់ថា, ប្រហែលជាមែនដឹង ព្រោះគិតមកដល់សម័យនេះគង់ជួបប្រទះឃើញមានខ្លះ ៗ ម្យ៉ាងទៀត អ្នកកសាងវត្ត មានបំណងចង់បានបុណ្យអំពីទីសេនាសនៈសំរាប់សង្ឃ ព្រោះមាននិទានរឿងជោតិកសេដ្ឋី ដែលមានប្រាសាទទេវតានិម្មិតឲ្យសុទ្ធតែកែវ ព្រោះអានិសង្សសាងកុដិថ្វាយព្រះពុទ្ធជាម្ចាស់ ៗ អនាថបិណ្ឌិកសេដ្ឋីសាងវត្តព្រះជេតពនថ្វាយព្រះពុទ្ធអង្គ អស់ប្រាក់ពីឃ្លាំង ដោយ

អំណាចកុសលផលបុណ្យនោះជួយឲ្យសម្បត្តិហូរចូលឃ្លាំងពេញដូចដើមវិញ ។ សទ្ធាជ្រះថ្លារបស់សាមញ្ញជន ដែលខំសាងវិហារដោយចង់បានផលដូចនេះឯង ។

ម្យ៉ាងទៀត អ្នកសាងវត្តអារាម ដោយចង់បានឲ្យវត្តនៅជិតភូមិលំនៅខ្លួន ដើម្បីងាយដើរទៅមកធ្វើបុណ្យទានផង ដើម្បីឲ្យកូនចៅស្រួលទៅរៀនសូត្រអំពីសំណាក់លោកចៅអធិការដែលបង្ហាត់បង្ហាញវិជ្ជាទាំងឡាយ ឲ្យបានចេះដឹងស្គាល់គុណទោសខុសត្រូវក្នុងលោកនេះនឹងលោកខាងមុខផង ។

## ៣ និយាយពីរបៀបនិមន្តលោកធ្វើមេវត្ត

អ្នកស្រុកកសាងវត្តថ្មី ពីមុនមកធ្លាប់ចំណុះវត្តណា ចូលចិត្តស្រឡាញ់ភិក្ខុឬគ្រូសូត្ររូបណា ត្រូវនាំគ្នាទាំងប្រុសស្រីជាច្រើនទៅសុំឲ្យលោកជាចៅអធិការវត្តនោះចាត់ភិក្ខុ ឬគ្រូសូត្រនោះមកធ្វើមេវត្តថ្មី ។ បើគ្មានកំណត់រូបលោកណាទេ ក៏ស្រេចនៅលោកចៅអធិការ ចាត់លោកអង្គណាដែលគួរធ្វើជាមេវត្តបាន ឲ្យមកធ្វើជាមេវត្តថ្មី ។ បើលោកព្រមចាត់ឲ្យហើយ, វត្តនោះមានភិក្ខុច្រើន សូមនិមន្ត ៤ ឬ ៥ រូបដែលខ្ចីវស្សាជាងមេវត្តថ្មីឲ្យនិមន្តមកជាមួយ មកគង់វត្តថ្មីផង ។ អ្នកស្រុកឲ្យអាចារ្យមើលឫក្សថ្ងៃនឹងទទួលលោកឲ្យចូលមកគង់វត្ត ។ អាចារ្យមើលឫក្សថ្ងៃពេលាល្អបានហើយ, ត្រូវរៀបរណ្តាបគង់វត្ត ហើយនាំគ្នាទៅទទួលលោក

ពីវត្តមក ហែហាមជាអ៊ុកធីក ទាំងលោកចៅអធិការជាមេវត្តថ្មី ក៏និមន្ត មកជាមួយ ; លុះមកដល់វត្តហើយ អ្នកស្រុកឬអាចារ្យអុជទៀនធូបប្រាប់ អ្នកតា ទេវតា ព្រះភូមិ នាងគង្ហីងព្រះធរណី ថាបាននិមន្តលោកឈ្មោះ នេះមកគង់ធ្វើជាមេវត្តនេះ ព្រមទាំងភិក្ខុជាបរិសទ្យ សូមឲ្យបានសេចក្ដី សុខចម្រើនរុងរឿងឋិតថេរចិរកាលតទៅ ។ ដល់ពេលល្ងាច រៀបចំវេន ព្រះបរិត្ត ( សូត្រមន្ត ) ព្រឹកឡើងប្រគេនភត្តរួចវេរដីខេត្រវត្ត ព្រមទាំង សាលា កុដិ រោងឧបោសថ ប្រគេនលោកមេវត្តថ្មី ជាស្រេចកិច្ច ។

ថ្ងៃក្រោយមក ត្រូវសុំអនុញ្ញាតចំពោះសម្ដេចសង្ឃរាជ សុំឲ្យ តាំងលោកមេវត្តនេះជាទីចៅអធិការ, សម្ដេចទ្រង់បានអនុញ្ញាតតាំងជាចៅ អធិការហើយ, ចៅអធិការនេះ ចូលគាល់សម្ដេច ។ ប្រទានទឹកស្រោច ជាចៅអធិការ ឲ្យពរស័ព្ទសាធុការ ព្រមទាំងប្រគល់សញ្ញាប័ត្រ ។

## សូមអភ័យទោសអំពីសំណាក់លោកអ្នកប្រាជ្ញ

សេចក្ដីចរចាខាងលើនេះមានបំពាននឹងសេចក្ដីហាមខ្លះ ឆ្លើយមិន ត្រូវតាមសួរខ្លះ ឆ្លើយហួសសួរក៏មានខ្លះ ទាំងមិនបានរៀបរយដោយចាំ មិនសព្វគ្រប់ ព្រោះពោលតាមដែលបានឮឃើញហោករៀបរៀប កសាងវត្តថ្មី, និមន្តចៅអធិការថ្មី នឹងចំឡាក់ក្បាលនាគ, សន្ទឹកជានាគ សៀម, ជាងឆ្លាក់ក្បាច់ហោជាង ។ ដ្បិតខ្ញុំបាទបានឃើញវិហារចាស់ខ្លះ ដែលមានជិភជងក្ដារគ្មាននាគ ដូចនិយាយក្នុង ១ ទី ៤ នោះ តាំងពីខ្ញុំបាទ

អាយុ ៧ – ៨ ឆ្នាំមកម៉្លេះ ឥឡូវខ្ញុំបាទអាយុ ៦៥ ឆ្នាំហើយ ។ រឿងដែលខ្ញុំបាទរៀបរៀងជូនលោកអ្នកប្រាជ្ញពិនិត្យទំនៀមទម្លាប់ តាមបានឃើញបានចាំមកនេះ ឥតមានប្រាជ្ញាជាប់លេខ ឬ សន្មតថាត្រឹមត្រូវនោះទេ ។ ហេតុនេះខ្ញុំបាទនឹងដាក់សេចក្ដីថាសុំរង្វាន់ បែបនេះ បែបនោះ ក៏នឹកអៀនខ្លួនខ្មាសលោកអ្នកប្រាជ្ញពន់ពេក ហាក់ដូចជាខ្ញុំបាទសង្ឃឹមថាជាប់លេខ មុនលោកអ្នកប្រាជ្ញពិនិត្យ ។

**កែវ – ហង់**

ទ្រាជ្ញាចុះអាជីកាំភាំង

រីទំនៀមនិងទម្លាប់ជាប់មានមក
ប្រាជ្ញគួរយកបញ្ញាអារកាត់សេចក្ដី
បើឃើញថាទំនៀមណាពុំពិសី
គួរកុំបីស្ដាយធ្វើអ្វីលះបោលបេញ ។
បើឃើញថាទំនៀមណាត្រូវផ្លូវធម៌
គួរខំបរកធ្វើឡើងឲ្យពេញលេញ
ធ្វើយ៉ាងនេះយ៉ាងហ្នឹងទើបបំណោញ
បានតាមពេញជាបណ្ឌិតពិតប្រាកដ ។

**ឃួរ — អ៊ិន**

## ពុទ្ធសាសនា និង ពាហិរសាសនា

## លោក ម៉ុញ-តាំគ្រី រៀបរៀង

(ត - ចប់)

### សាសនាសិន្តូ

ពាក្យថា "សិន្តូ" សំគាល់សេចក្តីថា "វិថីផ្លូវរបស់ព្រះជាម្ចាស់"ៗ

សាសនានេះ កើតឡើងក្នុងប្រទេសជប៉ុន ។ គោលសំខាន់របស់សាសនានេះគឺ ការបូជាធម្មជាតិ និងបូជាបុព្វបុរស ។ ឯបុព្វបុរសសំខាន់បំផុតគឺស្តេចម្ចាស់ផែនដី, ព្រោះសាសនានេះប្រដៅគ្នាថា ប្រទេសជប៉ុនជាបំណែករបស់ដួងព្រះអាទិត្យ ដែលផ្ទុះពេយពាយចុះមកជាកោះតូចៗ, តមកព្រះអាទិត្យបានប្រទានគូបុរសស្ត្រីជាដំបូងគឺព្រះពជានិងព្រះពជននី ទើបកើតជាកូនចួនជាចៅជាតិជប៉ុនរៀងមកដល់សព្វថ្ងៃនេះ ។

សេចក្តីស្អាតជាកិច្ចធំបំផុតសម្រាប់សាសនានេះ ព្រោះមានសេចក្តីបញ្ញត្តិសម្រាប់សាសនាបង្គាប់ថា ការចូលទៅជិតទីបូជារបស់សិន្តូត្រូវងូតទឹកសំអាតកាយឲ្យស្អាតសិន, ការចូលទៅជិតមនុស្សស្លាប់ក៏ដូចគ្នាទាំងត្រូវសំអាតចិត្តផង ។

មួយទៀតសាសនាសិន្តូជាសាសនាប្រដៅឲ្យជឿថា វិញ្ញាណជាវត្ថុមិនស្លាប់ ហេតុដូច្នោះការស្លាប់ក៏ទុកដូចជាផ្លាស់សម្លៀកបំពាក់ជាថ្មី និងមានឋានៈរឹតតែវិសេសឡើង ព្រោះជាទីគោរពបូជានៃជនានុជនទូទៅ ។

ហេតុនេះហើយបានជាក្នុងប្រទេសជប៉ុន មានវិធី "ហារាគិរី" គឺវិធីអត្តវិនិបាតកម្ម (សម្លាប់ខ្លួន) ដែលគេរាប់អានទូទៅថាជាកិច្ចប្រសើរសម្រាប់លាងបាប ជាកិច្ចសំដែងសេចក្តីសុចរិតសត្យវាទីឲ្យជាក់ស្តែង ។

កិច្ចនេះត្រូវធ្វើចំពោះមុខប្រជាជន មិនមែនលបលាក់ធ្វើដោយស្ងាត់ៗនោះទេ ។ ឯពិធីដែលត្រូវធ្វើនោះ ដំបូងសាមីរូបដែលដាច់ចិត្តត្រូវពាក់អាវពិធីសម្រាប់ត្រកូលរាល់គ្នា ហើយចូលទៅអង្គុយមុខតុៈពិធីដែលធ្វើពីឈើពណ៌ស ដែលមានដាក់កាំបិតនៅលើនោះ ។ កាំបិតនោះមានខ្នាតប្រវែង ៩ ធ្នាប់ ហើយរុំដោយក្រដាសពណ៌សច្រើនជាន់ទុកឲ្យនៅសល់តែចុងស្រួច ទើបយកកាំបិតនោះមកវះឆ្វៀតពោះឬវះជាជើងក្អែក ឲ្យមានប្រវែង ៦ ឬ ៧ ធ្នាប់ រួចហើយទើបអារកសំរេចជាខាងក្រោយ; ចួនកាលសាមីរូបអារកខ្លួនឯងមិនទាន់ស្រេចហៅឲ្យអ្នកជំនួយមកជួយបង្ហើយទេ ។ ឯអ្នកជំនួយនោះត្រូវរើសតែបុគ្គលដែលស្និទ្ធស្នាលដូចយ៉ាងមាតា-បិតា ឬញាតិសាច់មិត្រសំឡាញ់ដែលជិតដិត ៗ អ្នកជំនួយដែលបានជួយពិឃាតនេះទៀតសោត សឹងមានសេចក្តីពេញចិត្តនឹងកិច្ចនោះជាទីបំផុត ទុកដូចជាអ្នកដែលបានជួយបំបួសកុលបុត្រសម្រាប់ពុទ្ធសាសនាយើង ។

កិច្ចនេះ សម្រាប់ធ្វើបានតែពួកអ្នកដែលយល់ឃើញថាសុចរិតផង, បំណែកមនុស្សដែលមានទោសគួរដល់ពិឃាតជីវិតបង់ គេមិនព្រមឲ្យ

វិធីនេះទេ ត្រូវតែប្រហារជីវិតតាមច្បាប់រាជការ ។ សាសនានេះហើយដែលនាំឲ្យជាតិជប៉ុន មិនចេះរួញរានឹងសេចក្ដីស្លាប់ ។

សាសនាស៊ិន្តូ ជាសាសនាដើមរបស់ជប៉ុន, តែតមកខាងក្រោយ ព្រះពុទ្ធសាសនាផ្សាយចូលទៅដល់នាំឲ្យមនុស្សជ្រះថ្លាច្រើនជាង រហូតដល់ក្លាយទៅសាសនាសម្រាប់រាជការផែនដីជំនួសកន្លែងស៊ិន្តូបាន ។

ព្រះពុទ្ធសាសនាផ្សាយចូលទៅប្រទេសជប៉ុនរវាង ព. ស. ១០៩៥ ដោយព្រះចៅផែនដីកៅហ្វីបានបញ្ជូនព្រះពុទ្ធរូបទៅថ្វាយព្រះបាទ កិម្មេ-ៀ របស់ជប៉ុន, បន្ទាប់មកបានបញ្ជូនភិក្ខុឲ្យចូលទៅប្រកាសសាសនាក្នុងប្រទេសជប៉ុនទៀត ដរាបទាល់តែសម្បូរពុទ្ធសាសនិកនិកាយ ដល់ចំនួន ៤៨ លាននាក់ មានវត្តចំនួន ៧ ហ្មឺន, ឯសាសនាស៊ិន្តូមានចំនួនមនុស្សតែ ១៦ លានប៉ុណ្ណោះ ។

កាលបើព្រះពុទ្ធសាសនា ជាភ័យធំរបស់សាសនាស៊ិន្តូដូច្នេះហើយ អធិករណ៍ក៏កើតឡើងរវាងសាសនាទាំងពីរ, តែព្រះពុទ្ធសាសនាមានជ័យជំនះ គឺគេទុកជាសាសនាសម្រាប់ផែនដី ដរាបដល់មករាជ្យព្រះនាងឈុយកូ (ព. ស. ១១៣៦-១១៧១) ។

លុះដល់មករាជព្រះបាទមត្សុហិតូ (ព. ស. ២៤១០-២៤៥៥) ទើបប្រកាសផ្លាស់យកសាសនាស៊ិន្តូជាសាសនាសម្រាប់រាជការវិញ ដើម្បីឲ្យជនជាតិជប៉ុនមានលក្ខណៈជាជប៉ុនសុទ្ធទាំងសាសនាសម្រាប់ជាតិផង ។

ចប់

ពន្លឺអាស៊ីទ្វីប

# លោកប៉ាយ-ប៊ុក ក្រមការនៅពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

(តទក)

ឪបក្សាទាំងអស់ដែលរស់នៅសប្បាយស្រួលនឹងរុក្ខជាតិព្រឹក្សព្រៃ, សេកដែលមានស្លាបហើរលឿន, បក្សាស៊ីឪម៉ាល់, ពពូល, ព្រាប ! អ្នកទាំងអស់ឥតមានស្អប់ខ្ពើមនូវជីវភាពរបស់អ្នកឡើយ ហើយមានប្រាថ្នាចង់រចនាជីវភាពនោះឲ្យបានថ្លៃថ្លាឡើង ដោយធ្វើទុក្ខលំបាកខ្លួនឯងឬ? តែមនុស្សដែលធ្វើឃាតកម្មចំពោះអ្នកជាពួកបណ្ឌិត្យ ហើយប្រាថ្នាអ្នកនោះប្រឡាក់មន្ទិលលោហិត, អាចឲ្យចំរើនឡើង ក្នុងពេលដែលទទួលទុក្ខលំបាកដែលអ្នកនោះធ្វើចំពោះខ្លួន ដោយយល់ឃើញថា ខ្លួនជានាយកលើពិភពលោកឬ ?» ។

ក្នុងខណៈដែលព្រះបរមពោធិសត្វមានព្រះបន្ទូល ព្រះអង្គបានទតទៅឃើញធូលីដីហុយពីខាងភ្នំមក ដោយមានហ្វូងពពែញីស និងចៀមខ្មៅដើរមួយៗ ឈប់បង្អង់ចាំបរិភោគនៅតាមគុម្ពោតព្រៃដែលឃ្លាតចេញពីផ្លូវ តម្រង់ទៅខាងស្ទឹងឬទៅទីដែលមានផ្លែជ្រៃសំយុងចុះពីមែក, តែដល់កាលណាសត្វទាំងនោះដើរឃ្លាតចេញពីផ្លូវ, អ្នកឃ្វាលក៏ស្រែកដោយសំឡេងខ្លាំង យកដុំថ្មចោលហើយកៀងសត្វទាំងនោះឲ្យទៅខាងទី

ពល; នៅក្នុងហ្វូងនោះមានចៀមញីមួយនឹងកូនពីរ, កូនមួយនោះនាយគង្វាលចោលត្រូវគ្រេចជើងម្ខាង ហើយដើរតាមហ្វូងនោះបានដោយលំបាក, កូនមួយទៀតដើរទៅខាងមុខ, ឯចៀមញីក៏ដើរទៅក្រោយម្តងទៅមុខម្តងការពារកូននោះមិនឲ្យហ្វាង ។ ព្រះពោធិសត្វលុះទ្រង់បានឃើញដូច្នោះ ក៏មានព្រះទ័យករុណាអាណិតអាសូរ ព្រះអង្គលើកបីបមថ្នមកូនចៀមដែលរបួសនោះ ហើយមានព្រះបន្ទូលនឹងមេថា: “ឱនាងជាមាតាអើយ, នាងកុំព្រួយឡើយ · បើនាងទៅដល់ទីណា យើងក៏យកកូនទៅឲ្យដល់ទីនោះដែរ: យើងត្រូវតែការពារកុំឲ្យសត្វរងទុក្ខលំបាក, មិនត្រូវអង្គុយពីចារណាសេចក្តីទុក្ខក្នុងលោកសន្និវាស នៅរូងគុហាភ្នំជាមួយនឹងពួកឥសីដែលកំពុងសូត្រធម៌នេះឡើយ” រួចព្រះអង្គមានព្រះបន្ទូលសួរទៅអ្នកគង្វាលថា: “ហេតុដូចម្តេចបានជាអ្នកនាំហ្វូងសត្វនេះទៅពល ក្នុងអស្តង្គតសម័យដូចនេះ? តើពីកាលណាមកបានជាក្នុងសាយណ្ហ-សម័យគេនាំហ្វូងសត្វមកទីនេះ?” ។ ឯពួកអ្នកគង្វាលក៏ក្រាបទូលព្រះអង្គថា: “គេបានបង្គាប់ឲ្យយើងខ្ញុំយកពពែញីចំនួន ១០០ ចៀម ១០០ ទៅបូជាយញ្ញ តាមព្រះរាជតម្រាសព្រះមហាក្សត្រិយ៍ថា ឲ្យយកទៅពីឃាតយប់នេះ ដើម្បីនឹងថ្វាយដល់ពួកទេវតា” ។ ព្រះពោធិសត្វមានព្រះបន្ទូលថា: “យើងទៅជាមួយនឹងអ្នកដែរ” រួចទ្រង់ស្តេចយាងទៅតាមក្រោយពួកអ្នកគង្វាលនោះ បីទាំងកូនចៀមទៅផង ។ ពិតមែនតែ

ធូលីដីហុយឆ្អឹតមេឃ ហើយទឹងកំដៅព្រះអាទិត្យក្តៅពន់ពេក ឯមេដៀម នោះ ក៏ស្រែកយំបណ្តើរ ក្រឡេកមើលកូនបណ្តើរ នៅជិតព្រះអង្គ ។ លុះដល់ព្រះអង្គទីងពួកអ្នកគង្វាល ព្រមទាំងហ្វូងសត្វ ទៅដល់ជិតស្ទឹងនោះ មានស្ត្រីម្នាក់មានក្អែកដូចព្រាប មុខស្រោចស្រប់ដោយទឹកភ្នែក ដៃទាំងពីរប្រណម្យថ្វាយបង្គំព្រះពោធិសត្វ ហើយពោលថា: " ព្រះអង្គ អើយ ? ពីម្សិលមិញទើបបានអាណិតអាសូរខ្ញុំព្រះអង្គនៅគុម្ពោតព្រៃ ដែលខ្ញុំព្រះអង្គបានរស់នៅម្នាក់ឯង ចិញ្ចឹមទារកទាំងនោះ, ឯកូនខ្ញុំព្រះអង្គ បានទៅលេងតាមសួនបុប្ផាព្រឹក្សព្រៃ បានជួបប្រទះនឹងពស់ពិសមួយវា ស្ទុះមកវ័ណ្ឌរុំកដៃ, កូនខ្ញុំព្រះអង្គក៏អង្អែលអណ្តាតពស់ដែលវាលៀនចេញ ពីមាត់នោះ, ឥឡូវស្រាប់តែកូនខ្ញុំព្រះអង្គមុខឡើងស្វាយ ហើយស្ងៀម ស្ងាត់លែងនិយាយអ្វីរួច, ខ្ញុំព្រះករុណា មិនអាចយល់ហេតុថាដូចម្តេច បានជាកូននោះឈប់លេង ហើយបបូរមាត់ធ្លាក់ពីសុដន់ ខ្ញុំព្រះអង្គដូច នេះ", មានបុរសម្នាក់ឆ្លើយថា "វាត្រូវពិសពស់ចឹក កូននាងឯងនោះវា ជិតស្លាប់ហើយ", តែខ្ញុំព្រះអង្គសុំឱសថដែលពូកែស័ក្តិសិទ្ធិ អាចធ្វើឲ្យ ភ្នែកកូនខ្ញុំព្រះអង្គបើកបាន មើលឃើញរស្មីព្រះសុរិយា ស្នាមរបួសដែល ពស់ចឹកនោះតិចណាស់, សត្វនោះបើតាមខ្ញុំព្រះអង្គយល់ មិនគួរនឹងស្អប់ ហើយធ្វើឲ្យក្មេងដែលប្រឡែងជាមួយនឹងវារបួសសោះឡើយ ; មានបុរស ម្នាក់ទៀតពោលថា: " មានសទ្ធបុគ្គលម្នាក់នៅកងគុហាភ្នំ, នាងឯង

ឃើញទេ នោះហ្ន៎! លោកនិមន្តមកនេះ, គឺលោកដែលស្លៀកសំពត់លឿង, នាងឯងចូរសួរឥសីនេះ តើមានមធ្យោបាយយ៉ាងណាដែលជាអាថ៌កំបាំង ដើម្បីនឹងធ្វើឲ្យសះស្បើយរោគដែលកើតចំពោះកូននាងឯង, ខ្ញុំព្រះអង្គក៏បានចូលមកដល់ព្រះអង្គ ដែលមានព្រះតេជៈភ្លឺចាំង ខ្ញុំព្រះអង្គយំសោកស្តាយកូននេះពន់ពេក បានបើកសំពត់ដែលបិទមុខកូន ហើយសូមឲ្យព្រះអង្គប្រាប់ តើមានឱសថអ្វីដែលអាចធ្វើឲ្យកូនខ្ញុំព្រះអង្គដឹងខ្លួនវិញបាន, ពេលនោះ ព្រះអង្គនឹងមានព្រះបន្ទូលថា ឲ្យខ្ញុំព្រះអង្គចាកចេញពីទីនេះក៏ទៅដែរ តែព្រះអង្គបានទតក្មេងនោះដោយព្រះចក្ខុស្រងូតស្រងាត់ បានយកព្រះហស្តស្ទាបក្មេងនោះ ហើយត្រាស់ថា "អើនាង, មានតែវត្ថុមួយមុខទេដែលអាចធ្វើឲ្យសះស្បើយរោគនាងនឹងកូននាង បើនាងរករបស់នោះបាន, ព្រោះថាបើអ្នកណាទៅស្នើគ្រូពេទ្យៗនោះតែងបង្គាប់ឲ្យយកឱសថនេះទៅផឹក ព្រោះហេតុដូចនេះ ខ្ញុំសូមឲ្យនាងរកគ្រាប់មូតារដ៍ខ្មៅ (Moutar Noire) ចំនួន ១ តុលា[១] តែនាងប្រយ័ត្ន ត្រូវកុំយកអំពីផ្ទះណាដែលមានបិតា មាតា បុត្រឬទាសកម្មករណាមួយ ធ្វើមរណភាពនៅទីនោះ" តើព្រះអង្គមានវាចាដូចខាងលើនេះមែនឬ? ។

ព្រះអង្គទ្រង់ញញឹមដោយមានព្រះទ័យអាណិតអាសូរនាងនោះពន់

---

១ តុលា ទម្ងន់មួយរូពីប្រមាណ ៨ ក្រាម ។

ពេក ទើបត្រាស់ថា: "អើនាង! បើយើងបានពោលពាក្យនោះមែន, តើនាងឯងរកគ្រាប់មូតារ្ដ៍នោះបានឬ?"

— ទូលព្រះអង្គ! ខ្ញុំព្រះអង្គបានត្រាច់ទៅតាមគេហដ្ឋាន ហើយបានបីបុត្រដែលមានកាយត្រជាក់នោះទៅជាមួយផង បានសួរគេពីគេហដ្ឋានមួយទៅគេហដ្ឋានមួយនៅក្នុងព្រៃធំ (jungle) នឹងក្នុងនគរថា: សូមលោកមេត្តាខ្ញុំ! សូមលោកឲ្យខ្ញុំសុំនូវគ្រាប់មូតារ្ដ៍ខ្មៅ ចំនួនមួយតុលា" ហើយអ្នកណាដែលមានគ្រាប់នោះក៏គេឲ្យមកខ្ញុំ ពីព្រោះអ្នកក្រច្រើនមានចិត្តល្អចំពោះអ្នកក្រដូចគ្នា, ប៉ុន្តែខ្ញុំសួរទៅគេវិញថា "តើនៅគេហដ្ឋានអ្នកពីដើមមានស្វាមី, ភរិយា, បុត្រឬបាវព្រាវធ្វើមរណកាលដែរឬ?", អ្នកទាំងនោះតបមកខ្ញុំព្រះអង្គថា "ឱនាង! ចុះនាងសួរដូចនេះធ្វើអ្វី?, មនុស្សស្លាប់មានច្រើន មនុស្សរស់មានតិច" ខ្ញុំព្រះអង្គក៏ធ្វើអភិវន្ទនាលាចេញពីទីនោះ ដោយទឹកមុខស្រងូតស្រងាត់ ហើយក៏ប្រគល់គ្រាប់មូតារ្ដ៍នោះឲ្យទៅគេវិញ ខ្ញុំព្រះអង្គបានទៅសួរអ្នកដទៃទៀត តែអ្នកនេះពោលមកកាន់ខ្ញុំព្រះអង្គវិញថា: "នេះគ្រាប់មូតារ្ដ៍, តែនៅទីនេះមានស្លាប់ទាសកម្មករម្នាក់" ខ្លះថា "នេះគ្រាប់មូតារ្ដ៍, តែស្វាមីខ្ញុំអនិច្ចកម្មទៅហើយ" ខ្លះទៀតតបថា: "នេះគ្រាប់មូតារ្ដ៍ តែអ្នកដែលព្រោះពូជគ្រាប់នេះរំលាងខន្ធទៅកាន់បរលោក ក្នុងរវាងវស្សានរដូវ នឹងរដូវប្រែទៅហើយ" ទូលព្រះអង្គ! ខ្ញុំព្រះអង្គមិនអាចស្វែងរកគ្រាប់មូតារ្ដ៍

នៅគេហដ្ឋានណាមួយដែលគ្មានបុគ្គលស្លាប់នោះបានឡើយ! ព្រោះហេតុដូចនេះ បានជាខ្ញុំព្រះអង្គទុកកូនដែលឈប់ចៅស៊ុជន់, មានមុខឥតញញឹមសោះនៅប្របមាត់ទន្លេ ជិតដើមទំពាំងបាយជូ ហើយវិលត្រឡប់មកមើលព្រះភ័ក្ត្រព្រះអង្គ, ថើបព្រះបាទា, អង្វរព្រះអង្គ តើនៅទីណាខ្ញុំព្រះអង្គនឹងរកគ្រាប់មូតារដ៍នោះបាន ដោយកុំឲ្យឃើញសេចក្ដីស្លាប់ បើសិនជាកូនខ្ញុំព្រះអង្គមិនទាន់ស្លាប់នៅឡើយទេ កុំពេលដូចជាខ្ញុំមានសេចក្ដីភ័យតក់ស្លុតជាខ្លាំងហើយ ដូចជាមានគេប្រាប់ខ្ញុំ” ។

ព្រះពោធិសត្វតបថា: “ នុនាង! បើនាងស្វែងរកតែដែលគ្មានអ្នកណានឹងរកបាន, នាងទើបអាចរកឃើញនូវឱសថដែលមានរសជាតិល្វីងដែលយើងនឹងប្រគល់ជូននាង, កូនជាទីស្រឡាញ់របស់នាងនោះមរណភាពទៅហើយ; ឥឡូវនេះ នាងជ្រាបឬទេ? ថាក្នុងលោកសន្និវាសនេះ គេតែងតែយំសោកទទួលនូវសេចក្ដីទុក្ខគ្រប់យ៉ាងដូចនាងដែរ, សត្វទាំងអស់តែងទទួលសេចក្ដីលំបាក ខុសគ្នាតែខ្លះលំបាកតិច ខ្លះលំបាកច្រើន; នាងឃើញទេ? យើងសុំបង្ហូរលោហិតយើង បើសិនជាពលិកម្មនេះអាចការពារកុំឲ្យនាងយំសោកបាន សូមនាងបង្ហាញប្រស្នាអាថ៌កំបាំងចំពោះទុក្ខនោះ! ប្រស្នាដែលធ្វើសេចក្ដីស្នេហាជាហេតុឲ្យកើតទុក្ខនោះ នាំចិត្តមនុស្សឲ្យនាំសត្វទាំងនេះព្រមទាំងមនុស្សទីងអ្នកគង្វាលទៅតាមវាលដើម្បីនឹងបូជាយ័ញ្ញ ឥឡូវកំពុងរកប្រស្នាគម្ពីរភាពនេះ, ឯចំណែកនាង ចូរយកបុត្រនេះទៅកប់ទៅ” ។ (មាតគ)

## សប្បុរិសធម្មកថា

# ព្រះទេពសត្ថាសួរ-ឃាយ រៀបរៀង

(ត-ចប់)

---

ទីណាឬប្រទេសណាដែលសម្បូរដោយមនុស្សសប្បុរស, ទីនោះ ប្រទេសនោះរមែងប្រព្រឹត្តទៅដើម្បីសេចក្តីសុខ សេចក្តីចំរើន ដោយពិតប្រាកដឥតអាក់; កុំថាឡើយដល់ទៅសង្គ្រាម សូម្បីតែចោរលួចប្លន់ក៏ពុំមានឡើយ ៗ មួយវិញទៀត ធម៌របស់សប្បុរស ឬធម៌សម្រាប់សំគាល់ឲ្យដឹងថាអ្នកនេះជាមនុស្សសប្បុរសឬអសប្បុរសនោះ លោកហៅថា សប្បុរិសធម៌ មាន ៧ យ៉ាង:

១– **ធម្មញ្ញុតា** សេចក្តីដឹងធម៌ សំដៅយកការដឹងហេតុនៃសេចក្តីសុខទុក្ខ ហើយកាន់យកហេតុនៃសុខលះបង់ហេតុនៃទុក្ខចេញ ៗ

២– **អត្ថញ្ញុតា** សេចក្តីដឹងអត្ថ គឺដឹងផលនៃសេចក្តីសុខទុក្ខ ហើយតាំងចិត្តសន្តោស គឺត្រេកអរតាមមានតាមបាន ៗ

៣– **អត្តញ្ញុតា** សេចក្តីដឹងខ្លួន គឺដឹងថាអាត្មាអញមានជាតិត្រកូលថោកទាប ឬខ្ពង់ខ្ពស់យ៉ាងណា ហើយប្រព្រឹត្តខ្លួនឲ្យសមគួរ មិនឲ្យជាទំនាស់ដល់អ្នកដទៃ ៗ

៤ - **មត្តញ្ញូតា** សេចក្ដីដឹងប្រមាណ គឺដឹងច្បាស់ក្នុងការស្វែងរក, ក្នុងការទទួលយក, ក្នុងការបរិភោគប្រើប្រាស់ ចំពោះវត្ថុផ្សេងៗ ហើយអាចបេះលៃលកឲ្យសមគួរដល់ប្រមាណ, ប្រកបដោយធម៌សន្ដោសសមគួរដល់ប្រទេសជាតិរបស់ខ្លួន, មិនស្ទុះស្ទារមិនលោភឡើង ឲ្យហួសហេតុពេកខុសទំនង ដែលនាំឲ្យខូចតម្លៃកិត្តិយសរបស់ជាតិសាសនារបស់ខ្លួន ព្រោះតែឧបាយបាយរបស់គេនោះឡើយ ។

៥ - **កាលញ្ញូតា** សេចក្ដីដឹងកាល គឺដឹងថាកាលវេលានេះគួរប្រកបកិច្ចការនោះៗ, កាលវេលានេះជាកាលមិនគួរប្រកបកិច្ចការនោះៗទេ ។

៦ - **បរិសញ្ញូតា** សេចក្ដីដឹងបរិសទ្យ គឺដឹងថាប្រជុំជននេះមានឋានៈបែបនេះមានកិរិយាបែបនេះ ហើយប្រព្រឹត្តខ្លួនតម្រូវឲ្យសមគួរដល់អធ្យាស្រ័យនៃបរិសទ្យនោះ ។

៧ - **បុគ្គលបរោបរញ្ញូតា** សេចក្ដីដឹងបុគ្គលជាន់ខ្ពស់-កណ្ដាល-ទាប គឺដឹងថាបុគ្គលនេះជាមនុស្សសប្បុរស គឺមនុស្សល្អដែលគួរសេពគប់, បុគ្គលនេះជាមនុស្សអសប្បុរស គឺមនុស្សអាក្រក់ដែលមិនគួរសេពគប់ជាដើម ។

សប្បុរិសធម៌ ៧ ប្រការនេះ ទុកជាត្រាប្រថាប់ឬជាសញ្ញាប័ត្រមួយសម្រាប់ឲ្យទាយបានថា : បើនរណាមានធម៌ ៧ ប្រការនេះ នរៈនោះ

ទើបឈ្មោះថាជាមនុស្សសប្បុរសដោយពិត, បើបុគ្គលណាមិនមានធម៌ ៧ ប្រការនេះទេ, បុគ្គលនោះក៏បានឈ្មោះថាជាមនុស្សអសប្បុរស ។

មនុស្សយើងដោយប្រក្រតីរមែងមានធម៌ទាំងនេះតាំងនៅក្នុងខ្លួនខ្លះមិនខាន, បើមិនមានច្រើនក៏គង់មានតិច ៗ អ្នកដែលមានធម៌នេះតិចមិនគប់គ្រាន់ក្នុងសន្តាន រមែងទៅជាមនុស្សមានសេចក្ដីអង់អាចតិច, មានសេចក្ដីសុខសេចក្ដីចំរើនក៏តិចតាមលំដាប់ ។ អ្នកដែលមានធម៌ទាំងនេះច្រើនក្នុងសន្តាន រមែងបានជាមនុស្សមានសមត្ថភាព, ថ្លៃថ្នូរ, មោះមុតអង់អាចច្រើន ធ្វើប្រយោជន៍ដល់ខ្លួនទីងជាតិសាសនារបស់ខ្លួនក៏បានច្រើន; ទាំងសេចក្ដីសុខសេចក្ដីសរសើរទីងកេរ្តិ៍ឈ្មោះយសស័ក្តិក៏មានច្រើន ។

ព្រះពុទ្ធសាសនា ជាបដិបទាឲ្យកើតសន្តិសុខដោយសុតសុភាពសម្រាប់ដឹកនាំមនុស្សឲ្យទៅជាសប្បុរស ។ ឯពាក្យថា "សន្តិសុខ" នេះសំដៅយកសេចក្ដីសុខសាន្ត ទាំងលោកនេះនិងលោកខាងមុខ ។ មួយទៀត សេចក្ដីសុខនេះមាន ២ យ៉ាង គឺ សេចក្ដីសុខដែលកើតអំពីការស្ងប់រម្ងាប់ ចាកទុក្ខទោសពៃរ៍ភ័យសត្រូវ ជាសេចក្ដីសុខរបស់ប្រទេសជាតិ របស់មនុស្ស របស់ទេវតា ដែលនៅលាយឡំដោយទុក្ខខ្លះ ហៅថា សាមិសសុខ ១; សេចក្ដីសុខស្អាតបរិសុទ្ធដែលកើតអំពីការស្ងប់រម្ងាប់ចាកកិលេស ចាកបញ្ចក្ខន្ធ គឺជាសុខដែលមិនលាយឡំដោយទុក្ខទោសពៃរ៍គេទៅទៀត បានដល់សេចក្ដីសុខរបស់ព្រះនិព្វាន នេះ

លោកហៅថា និរាមិសសុខ ១ ។ ព្រះពុទ្ធសាសនា តែងឲ្យសម្រេចផលដ៏ខ្ពង់ខ្ពស់ គឺសុខ ២ ប្រការនេះឯង ។

ព្រះពុទ្ធសាសនា ប្រៀបដូចជាផ្ទះផ្សារមួយខ្នង ដែលមានទំនិញល្អៗច្រើន ហើយជាទំនិញសុទ្ធតែវត្ថុបរិសុទ្ធ មិនមែនជារបស់ក្លែងក្លាយ ឬមានពិសពុលក្តៅក្រហាយ ដូចកាន់ផ្សារគឺសាសនាឯទៀតៗ នោះទេ ។ ផ្សារគឺពុទ្ធសាសនានេះ បើកលក់បំពោះតែរបស់ណាមួយដែលមិនជាសំត្រូវ ។ ទំនិញដែលបរិសុទ្ធនោះ គឺមគ្គប្រកបដោយអង្គ ៨ ប្រការ មានសម្មាទិដ្ឋិជាដើម នឹងកុសលធម៌ទាំងឡាយឯទៀតៗជាច្រើន, គួរតែប្រជាជនក្នុងលោកចូលមកទិញទំនិញល្អៗនោះតាមត្រូវការ ។ ព្រះពុទ្ធសាសនា មានបញ្ញត្តិសិក្ខាបទជាសាធារណៈដល់មនុស្សនឹងមនុស្សផងគ្នា ព្រមទាំងដល់មនុស្សនឹងសត្វតិរច្ឆាន ឥតមានរើសជាតិឡើយ, ទោះបីមនុស្សក៏ត្រូវមានធម៌សុចរិតក្នុងរវាងសត្វតិរច្ឆាន ។ ព្រោះសត្វតិរច្ឆានមានជីវិតជាទីស្រឡាញ់ មានមេ មានបា មានកូន ជាទីស្រឡាញ់របស់វាយ៉ាងណា ; មនុស្សយើងក៏យ៉ាងនោះដែរ ។ សាសនាឯទៀតៗក្រៅពីនេះ ឬច្បាប់បញ្ញត្តិរបស់ប្រទេសទាំងឡាយក្នុងលោក ច្រើនតែបញ្ញត្តតែងវិន័យតែក្នុងរវាងមនុស្សនឹងមនុស្ស ដូចយ៉ាងផ្តេវបាណាតិបាត ឬអទិន្នាទានជាដើម ចំពោះតែមនុស្សផងគ្នា, ត្រង់មនុស្សសម្លាប់តិរច្ឆានឬលួចប្លន់ដណ្តើមស៊ីតសត្វតិរច្ឆានកូនទៅសត្វតិរច្ឆាន មិនឃើញមានបញ្ញត្តិផងឡើយ ។

បុគ្គលជាមនុស្សជាតិណាមួយ កាន់ធម៌សុចរិតទៀងទាត់ពិតត្រង់ក្នុងការរបស់ប្រទេស របស់សាសនា ទាំងរវាងមនុស្សនឹងមនុស្សដូចគ្នា, ទោះបីជាមនុស្សជាន់ទាបឬជាន់ខ្ពស់ ក៏មិនត្រូវប្រមាថមើលងាយបៀតបៀនរឹបជាន់ដល់គ្នានឹងគ្នាទេ, ទាំងមនុស្សក៏ត្រូវកាន់ធម៌សុចរិតចំពោះតិរច្ឆានផងដែរ ។ បុគ្គលអ្នកកាន់ធម៌តាមបញ្ញត្តិនៃព្រះពុទ្ធសាសនាដូច្នេះ ហៅថា សប្បុរស ។ មនុស្សសប្បុរសនេះ ច្រើនមានតែក្នុងព្រះពុទ្ធ-សាសនា ។ អ្នកដែលកាន់ធម៌សុចរិតរើសមុខដោយអាងថា ខ្លួនអញជាមនុស្សជាន់ខ្ពស់, ជាអ្នកមានយសស័ក្តិអំណាច, ជាមនុស្សមានកំឡាំងទ្រព្យធនច្រើន, ជាមនុស្សមានឧបាយកិច្ចកលច្រើន ហើយសង្កត់សង្កិនបៀតបៀនមនុស្សដែលថោកទាប, បៀតបៀនមនុស្សដែលឥតយសស័ក្តិ មើលងាយមនុស្សដែលក្រទាល់ទ្រព្យសម្បត្តិ, បោកប្រាស់បំបាត់មនុស្សដែលល្ងង់ខ្លៅដែលគ្មានឧបាយ; អ្នកដែលមានសេចក្តីប្រមាថពាយងាយដូច្នេះ ទោះបីបង្ខំខ្លួននៅក្នុងសាសនាក៏ហៅថា អសប្បុរស ដែរ ។

ពណ៌នាមកថាអំពីសប្បុរសធម្មកថា ក៏សមគួរដល់វេលា សូមសន្មតបញ្ចប់តែប៉ុណ្ណេះ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។

សត្វទាំងឡាយ ដែលដល់នូវទុក្ខ សូមឲ្យជាអ្នកបាត់ទុក្ខទៅ!

ដែលដល់នូវភ័យ សូមឲ្យបាត់ភ័យទៅ! ដែលដល់នូវសេចក្ដីសោក សូមឲ្យបាត់សោកទៅ!

រតនត្តយតេជេន កាម្ពោជរដ្ឋា សិវោ

វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ សន្តិភាវញ្ច គាញ្ឆតុ ។

ដោយតេជៈនៃព្រះរតនត្រ័យ សូមឲ្យប្រជាជនទាំងឡាយអ្នកកើតនៅក្នុងកម្ពុជរដ្ឋ ដល់នូវការលូតលាស់ចំរើនទីងសន្តិភាព កុំបីឃ្លៀងឃ្លាតក្លាយទៅជាប្រការដទៃឡើយ ។

ចប់

ធម៌ស្អាងខ្លួនបីយ៉ាង:

ពូជត្រកូល, ទទួលភ្ញៀវ, ឧបាគតខំ;
ត្រកូលឧត្ដមដោយសន្ទៀអប់រំល្អ,
ទទួលភ្ញៀវដោយមនោស្អាតស្មុំ,
ឧបាគតកដោយខំបរប្រព្រឹត្តិការ ៖
ធម៌ ៣ នេះគុណវិសេសសាងសួស្ដី
ដល់ប្រុសស្រីក្នុងលោកិយឲ្យអស្ចារ្យ
ជាធម៌ពិតជួយប្រសិទ្ធិដោតសង្ហារ
ឲ្យឋាវរកស្ថាពរទ្រខ្ពស់ឡើង ។

យូរ — អ៊ុន

# ពិធីបុណ្យដង្ហែព្រះសារីរិកធាតុ

## នៅវត្តដំណាក់ ខេត្តសៀមរាប

## ព្រះមហា កែ-អឿន រៀបរៀង

**ដោយទទួលថេរបញ្ជាការនៃព្រះតេជព្រះគុណព្រះសុខង្គលសីលាចារ្យមេគណ ស ខ ប**

---

កាលថ្ងៃចន្ទ ១៥ កើតខែពិសាខ ជាថ្ងៃបុណ្យវិសាខបូជា ឆ្នាំខាល ទោស័ក ព. ស. ២៤៩៣ ត្រូវនឹងថ្ងៃ ១ ខែឧសភា គ. ស. ១៩៥០ នេះ ពួកពុទ្ធបរិស័ទជាចំណុះជើងវត្តទាំង ៤ គឺៈ វត្តដំណាក់, វត្តព្រះព្រហ្មរតន៍, វត្តពោធិលង្កា, វត្តព្រះឥន្ទកោសា បានសាមគ្គីស្រុះស្រួលបបួលរួមគ្នា ចាត់ចែងធ្វើពិធីបុណ្យមួយដ៏ឧឡារិកនៅទីវត្តដំណាក់ ហៅថា "បុណ្យហែព្រះសារីរិកធាតុ" ។ នៅវេលាម៉ោង ៤ រសៀល ពួកពុទ្ធបរិស័ទវត្តទាំង ៤ បានមកជួបជុំគ្នានៅមុខវត្តដំណាក់; បណ្ដាពួកពុទ្ធបរិស័ទដែលបានអញ្ជើញមកទាំងប៉ុន្មាន មានសន្ដានជ្រះថ្លាក្នុងព្រះពុទ្ធសាសនា មានហត្ថាកាន់យកគ្រឿងសក្ការៈបូជាដ៏វិចិត្រ រចនាដោយបុប្ផាផ្កាឈើស្រស់, ផ្កាក្រដាស, ទៀនធូប, គ្រឿងក្រអូប, ទង់ជាតិ ។ ឯគ្រឿងដំកើងលើកដម្កល់ព្រះសារីរិកធាតុនោះ ជាងធ្វើព្រះស្តូបរចនាដោយប្រាក់ ជាន់ខាងក្នុងរចនាជាកោដ្ឋមាស ហើយដាក់ព្រះធាតុដម្កល់ទុកក្នុងទូតូចមួយជាន់ទៀត ។ គ្រឿងដម្កល់ហែ ជាងធ្វើជាបុស្បុក កំពស់ប្រមាណ ៥ ម៉ែត្រ ហើយដំកល់លើរថយន្តសណ្ដាន់មួយដ៏ប្រដាប់

គាត់តែងដោយក្បូរក្បាច់រំលេចរចនាដោយផ្កាឈើស្រស់ផ្កាក្រដាសទង់ជាតិតូចៗនឹងគ្រឿងសក្ការៈផ្សេងៗទៀត ។ ក្នុងពេលនោះ គេក្រឡេកមើលពីចម្ងាយទៅ ឃើញក្រុមពុទ្ធបរិស័ទប្រែនមីរដេរដាសកាន់គ្រឿងសក្ការៈបូជា ផ្លាស់ពណ៌ចំរុះទីទៃៗពីគ្នា គួរឲ្យមានសេចក្ដីរីករាយនឹងសេចក្ដីជ្រះថ្លាពន់ពេក ។ លុះពេលដឹតហែព្រះសារីរិកធាតុ, ភិក្ខុសាមណេរវត្តទាំងបួនបាននិមន្តទៅជួបជុំជាង ១០០ អង្គ លោកពជការគង់ក្រុងសៀមរាបគ្រប់តំណែង មានលោកពជការសាលាខេត្ត, ក្រសួងសិក្សាធិការ លោកចាងហ្វាងសាលាសិក្សាធិការ នឹងគ្រូបង្រៀនទាំងអស់ ព្រមទាំងកុមារកុមារីជាសិស្សានុសិស្សសាលារៀនជាដើម ក៏បានអញ្ជើញទៅជាមង្គលក្នុងពិធីបុណ្យនោះដែរ ។

កាលពុទ្ធបរិស័ទទាំងអំបាលនេះជួបជុំហើយ មុននឹងហែ អាចារ្យវត្តនាំគ្នានមស្ការព្រះរតនត្រ័យ, សូរស័ព្ទធម៌ឮគឹកកងរំពងឡើង ។ លុះចប់នមស្ការហើយ, មានថ្លែងសុន្ទរកថាដូចមានតទៅនេះ ៖

សូមបង្គំទូលព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ !

សូមជំរាបអស់លោកអ្នកជាពុទ្ធបរិស័ទទាំងឡាយ !

ថ្ងៃ ១៥ កើតខែវិសាខនេះ ជាថ្ងៃនក្ខត្តឫក្សរបស់អ្នកកាន់ព្រះពុទ្ធសាសនា គឺត្រូវជាថ្ងៃខួបព្រះសម្មាសម្ពុទ្ធជាបរមគ្រូយើងទ្រង់ប្រសូតិ, ទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ នឹងទ្រង់រំលត់ខន្ធចូល

កាន់ព្រះបរមនិព្វាន ; ថ្ងៃ ១៥ កើតខែវិសាខនេះ ក៏សន្មតថា ដូចជាថ្ងៃ ១៥ កើតខែវិសាខក្នុងកាលនោះ សឹងជាទីនិយមរាប់អានរបស់អ្នកប្រាជ្ញថាជាថ្ងៃមហាអស្ចារ្យនិងជាមហាមង្គលដ៏ប្រសើរ ព្រោះហេតុនោះ បានជាអ្នកកាន់ព្រះពុទ្ធសាសនាទាំងឡាយគ្រប់ប្រទេស កាលបើដល់ថ្ងៃពេញបូណ៌មីខែវិសាខ ដែលជាថ្ងៃអភិលិខិតកាលដូច្នោះហើយក៏នាំគ្នាចាត់ចែងគ្រឿងសក្ការៈដ៏ផ្ចិតផ្ចង់គ្រប់ដៃ មានប្រទីបធូបរលាទៀនធូបនិងកម្រងផ្កាជាដើម យកទៅបូជាគោរពវន្ទាចំពោះព្រះស្តូបជាទីបញ្ចុះព្រះសារីរិកធាតុ និងឧទ្ទេសិកចេតិយ គឺព្រះពុទ្ធបដិមាករ ដែលប្រតិស្ឋានទុកជាគ្រឿងសំគាល់នៅក្នុងអារាមផ្សេងៗ ឧទ្ទិសចំពោះព្រះសម្មាសម្ពុទ្ធដែលទ្រង់បរិនិព្វានទៅជាយូរអង្វែងឆ្នាំហើយ, រួបប្រជុំគ្នានមស្សការព្រះរតនត្រ័យ ស្តាប់ព្រះសង្ឃសូត្រស្វាធ្យាយនិងស្តាប់ព្រះសទ្ធម្មទេសនាជាទីរំលឹកដល់ថ្ងៃដែលព្រះសម្មាសម្ពុទ្ធជាបរមគ្រូនៃយើង ទ្រង់ប្រសូត, ត្រាស់ដឹង, បរិនិព្វាន តាមសេចក្តីជំនឿនិងសេចក្តីជ្រះថ្លារបស់ខ្លួនៗ ជាប់ជាប្រវេណីតៗ មកដល់សព្វថ្ងៃនេះ ។

ក៏ក្នុងថ្ងៃ ១៥ កើតខែវិសាខឆ្នាំនេះ អស់យើងទាំងឡាយជាពុទ្ធបរិស័ទមានគ្រឿងសក្ការៈគ្រប់ដៃ បានមកជួបជុំគ្នាហើយក្នុងទីមហាសន្និបាតនេះ ដើម្បីដង្ហែព្រះសារីរិកធាតុ នៃព្រះសក្យមុនីគោតមបរមគ្រូយើងដែលទ្រង់បរិនិព្វានទៅអស់កាលជាយូរអង្វែងឆ្នាំហើយ នៅសល់តែព្រះ

កិត្តិគុណនឹងព្រះបរមធាតុឲ្យយើងទីពឹងពំនាក់អាស្រ័យយកជានិស្ស័យទៅបរលោក ។ អស់លោកអ្នកទាំងឡាយ ! ព្រះធាតុដែលដំកល់នៅក្នុងទីចំពោះមុខនេះ ពិតជាព្រះសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ប្រាកដហើយ សូមលោក-អ្នកទាំងឡាយតាំងសតិឲ្យខ្ជាប់ ហើយញ៉ាំងបសាទសទ្ធា គឺសេចក្តីជ្រះថ្លាជឿជាក់ក្នុងព្រះពុទ្ធគុណ ប្រកបដោយឧស្សន្នកុសលចេតនា នមស្សការថ្វាយបង្គំនឹករលឹកដល់គុណព្រះពុទ្ធជានិច្ចកាលទៅ នឹងបានផលានិសង្សដ៏ប្រសើរពុំលែងឡើយ ។

ដោយគុណានុភាពនៃសេចក្តីជ្រះថ្លា ក្នុងព្រះរតនាទិគុណនៃយើងជាពុទ្ធបរិស័ទទាំងអស់គ្នានេះ សូមឲ្យយើងខ្ញុំបានប្រកបដោយសេចក្តីសុខសេចក្តីចំរើនគ្រប់ប្រការ វៀងរាល់ជាតិកុំបីឃ្លាត ដរាបដល់ព្រះនិព្វានជាបរិយោសានទៅហោង ។

លុះថ្លែងសុន្ទរកថាចប់ហើយ ពុទ្ធបរិស័ទទាំងឡាយក៏ចាត់ចែងដង្ហែព្រះសារីរិកធាតុតទៅ ។ ឯការហែនុះ បានរៀបចំជាក្បួនដូច្នេះ :

ក្បួនហែព្រះសារីរិកធាតុ

សង្កាត់ ទី ១ — ពួកកុមារកុមារី កាន់ទង់ជាតិ

" " ២ — ភ្លេងពិណពាទ្យ

" " ៣ — ភិក្ខុសាមណេរ

" " ៤ — បុស្បុកដំកល់ព្រះសារីរិកធាតុ

សង្កាត់ ទី ៥- ពួកស្រីៗ ក្មេង, ចាស់

" " ៦- ពួកប្រុសៗ ក្មេង, ចាស់

លុះរៀបចំជាក្បួនស្រេចហើយ ក៏គោះគងទូងគោរលេងភ្លេងពិណពាទ្យ ដង្ហែព្រះសារីរិកធាតុចេញពីមុខវត្តដំណាក់ទៅតាមវិថីមាត់ស្ទឹងត្រើយខាងកើត ដរាបទៅដល់ស្ពានថ្ម ឆ្លងស្ទឹងទៅត្រើយខាងលិចរហូតទៅដល់គេហដ្ឋានក្រមរដ្ឋករ បត់ចូលទៅតាមវិថីស្ទឹងថ្មីព័ទ្ធជុំវិញក្រុងសៀមរាប ហើយដង្ហែចូលទៅដម្កល់ទុកលើបុស្បុកក្នុងមុខយ៉ព្រះវិហារវត្តដំណាក់វិញ រួចនាំគ្នានមស្ការព្រះរតនត្រ័យម្តងទៀត ។ ចាប់ពីត្រឹមម៉ោង ៧ ល្ងាចនោះតទៅ ពួកពុទ្ធបរិស័ទទាំងឡាយក្នុងដំណាក់មានភិក្ខុសាមណេរជាដើម ក៏នាំគ្នាធ្វើវិសាខបូជាតាមទំនៀមដរាបដល់ភ្លឺ ។ ចំណែកខាងពុទ្ធបរិស័ទទាំងឡាយវត្តដទៃៗ ទាំងគ្រហស្ថទាំងបព្វជិត លុះផុតកិច្ចនមស្ការហើយ ក៏នាំគ្នាកាន់យកគ្រឿងសក្ការៈគប់ដៃអញ្ជើញនិមន្តទៅកាន់វត្តរៀងៗខ្លួន ធ្វើវិសាខបូជាតាំងពីពេលប់ដរាបដល់ភ្លឺដែរ ។

ដោយតេជានុភាពនៃកុសលកសិដ៏ប្រសើរក្នុងពេលនេះ យើងខ្ញុំព្រះអង្គសូមថ្វាយព្រះរាជកុសលចំពោះព្រះប្រិយមហាក្សត្រ ដែលព្រះអង្គជាអគ្គសាសនូបត្ថម្ភ ព្រមទាំងព្រះរាជវង្សានុវង្ស សូមឲ្យបានទ្រង់ស្ថិតនៅក្នុងសិរីរាជសម្បត្តិជាសុខក្សេមក្សាន្ត ។ សូមជូនកុសលនេះដល់

គណៈរដ្ឋមន្ត្រី និង សូមប្រគេនដល់ព្រះសង្ឃគ្រប់អារាម មន្ត្រីនិងបណ្ដាជនខ្មែរដែលអាស្រ័យនៅក្នុងក្របខ័ណ្ឌសីមាកម្ពុជរដ្ឋទាំងមូល សូមឲ្យបានប្រកបដោយសេចក្ដីសុខសេចក្ដីចំរើនគ្រប់ប្រការសព្វទិវាកាត្រីកាលកុំបីអាក់ខានឡើយ ។ សូមតេជះព្រះរតនត្រ័យដែលជាទីពឹងពំនាក់របស់ជាតិខ្មែរ សូមតេជានុភាពនៃពពួកទេវតា មានមហិទ្ធិឫទ្ធិនិងទេវតាមហេសក្ដិ ដែលទទួលថ្វាក់តំណែងចុះមកក្នុងឆ្នាំថ្មីនេះ ព្រមទាំងទេវតាដែលស្ថិតនៅក្នុងអនន្តរបក្រវាឡទាំងប៉ុន្មាន សូមជួយឲ្យប្រទេសកម្ពុជាជៀសវាងឆ្ងាយពីសេចក្ដីទុក្ខវេទនាផ្សេងៗ ឲ្យបានថ្កើងរុងរឿងឆាប់ដូចអំពីអតីតកាលឡើងវិញ, សូមជួយបណ្ដុះបណ្ដាលសតិបញ្ញាដល់បណ្ដាជនជាតិខ្មែរ ឲ្យបានកើនចំរើនឡើង ហើយខិតខំធ្វើការងារល្អៗដែលជាប្រយោជន៍ដល់ប្រទេសជាតិមាតុភូមិ លះបង់នូវសេចក្ដីខ្ជិលច្រអូសពីខន្ធសន្តាន ឲ្យជ្រះស្រឡះតាំងចិត្តសុចរិតប្រព្រឹត្តការងារដ៏វិសេស ឲ្យបានថ្កើងថ្កានឆាប់ដូចជាពពួកជននៅក្នុងអារ្យប្រទេសនានា កុំបីឃ្លៀងឃ្លាតឡើយ ។

ចប់

មានតែអ្នកដែលមិនធ្វើទេទើបមិនខុស ។

យូរ — អ៊ុន

## ពិធីបុណ្យស្រង់ទឹក

# សម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត

*សង្ឃនាយក គណៈមហានិកាយ វត្តឧណ្ណាលោម ក្រុងភ្នំពេញ*

គឺ

# ព្រះទេពសត្ថា សួរ-ហាយ

*ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង*

---

កាលពីថ្ងៃ៩-១០ រោចខែពិសាខ ឆ្នាំខាល ទោស័ក ព.ស. ២៤៩៣ (១០-១១ ខែឧសភា គ.ស. ១៩៥០) មានពិធីបុណ្យស្រង់ទឹកព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ ដោយហេតុបានទទួលសមណសក្តិជា " សម្តេចព្រះមហាសុមេធាធិបតី " អំពីព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់ប្រោសព្រះរាជទាន ដូចមានពិធីបុណ្យខាងក្រោមនេះ ៖

## ស៊ុំនៅខ្លោងទ្វារវត្ត

ខ្លោងទ្វារកំពែងវត្តនិងខ្លោងទ្វារកំពែងព្រះវិហារ មានការគាក់តែងស៊ុំ ដែលរចនាដោយរបៀបល្អវិចិត្រដូចគ្នាទាំងពីរកន្លែង, សសរស៊ុំសុទ្ធតែស្រោបដោយស្លឹកទន្សែរហូតដល់កំពូល, មានផ្ទាំងតួអក្សរធំៗ ដែលកាត់ក្រដាសពណ៌មាសបិទនៅស៊ុំទ្វារ, កំពូលស៊ុំទាំងពីរនោះមានដោតទង់ជ័យព្រោងព្រាត, ផ្លូវដែលចូលទៅអំពីខ្លោងទ្វារខាងក្រៅរហូតដល់ខ្លោង

ទ្វារខាងក្នុង. សឹងមានសសរទង់ជ័យជាពីរជួរ, សសរទាំងនោះសុទ្ធតែស្រោបដោយស្ទឹកដែក្រឹម ។

## រោងតាំងតុនៅធ្លាមុខព្រះវិហារ

នៅទីធ្លាមុខព្រះវិហារនឹងទីធ្លាក្នុងកំពែងព្រះវិហារ ជាទីដ៏ដេរដាសដោយរោងតាំងតុៈរៀបចំសក្ការបូជា ថ្វាយព្រះរតនត្រ័យ នឹងបុស្បុកបារាំធំតូច ដែលប្រដាប់ដោយគ្រឿងតាំងដ៏វិចិត្រផ្សេងៗ, មានអំពូលភ្លើងអគ្គិសនីជាដើម គ្រប់រោងតាំងតុទាំង ៨ នឹងបុស្បុកបារាំធំតូចទាំងអស់ ។

ឯរោងតាំងតុទាំង ៨ នោះ តាំងនៅអមផ្លូវចំមុខព្រះវិហារ គឺ ខាងត្បូងផ្លូវមានរោង ៤, ខាងជើងផ្លូវមានរោង ៤ ប្រឈមមុខរកគ្នា ព្រមទាំងបារាំ ១ ខ្នង ជារបស់លោកអ្នកឧកញ៉ាសិរិន្ទ្របវរស័ក្ដិចៅហ្វាយក្រុងភ្នំពេញ ( សាន - យុន ) ។ រោងទាំង ៨ នោះជារោងដែលពុទ្ធបរិសទ្យទាំងបព្វជិតទាំងគ្រហស្ថ មានចិត្តជ្រះថ្លាមកសង់តែរៀងៗខ្លួន តាមគំរូផែនទីដែលគណៈកម្មការបុណ្យបានសំដែងឲ្យ ។ ទំហំនឹងកំពស់នៃរោងទាំង ៨ នោះប៉ុនៗគ្នា ដូចគ្នាទាំងអស់គឺ ទទឹងនឹងបណ្ដោយរោងនីមួយៗប្រវែង ៣ ម៉ែត្រ ៥០ កំពស់ ៤ ម៉ែត្រ ។ បណ្ដារោងតាំងតុទាំង ៨ នោះ វត្តឧណ្ណាលោមមានក្រុម ៨ ទទួលរៀបរោងតាំងតុ ៤ ដោយការរួបរួមចូលគ្នា គឺមេក្រុមពីរៗ ទទួលចាត់ចែងរៀបចំរោងតាំងតុ ១ ។ ឯរោងតាំងតុ ៤ ទៀត ជារបស់វត្តទាំង ៩ ក្នុងក្រុងភ្នំពេញ គឺវត្តលង្កា,

វត្តមហាមន្ត្រី, វត្តកែវព្រះភ្លើង, វត្តព្រះពុទ្ធមានបុណ្យ, វត្តពិកុទ្រង្សី, វត្តរតនារាម វត្តសារាវ័ន, វត្តកោះ និង វត្តសំពៅមាស ។

ពេងតាំងតុទាំង ៨ ខ្នងនិងបារាំ ១ ខ្នងនោះ មានការរៀបចំដោយគ្រឿងលំអស្រស់ស្រដៀងៗគ្នា គួរឲ្យអ្នកផងជ្រះថ្លាជាប់ចិត្តចង់មើលហើយមើលទៀត ។ ពេងតាំងតុនីមួយៗ សុទ្ធតែដេរដាសទៅដោយកម្រងផ្កាឈើ-ស្លឹកជ្រៃក្រឹមនិងស្លឹកទន្សៃ ។ ខាងក្នុងពេងទាំងនោះសុទ្ធតែពាសដោយសំពត់ពណ៌លឿងខ្លះ, សខ្លះ, ខៀវខ្លះព័ទ្ធជុំវិញ ។ នៅលើតុក្នុងពេងនោះ សឹងមានវត្ថុយ៉ាងឆើតៗជាច្រើនមុខ មានព្រះពុទ្ធរូបចម្លាក់ខ្លឹមឈើនិងផើងផ្កាជាដើម ។ ក្នុងពេងនោះមានតែងរំលេចពន្លឺរស្មីភ្លើង ៣-៤ ពណ៌ ដែលលោកចៅហ្វាយក្រុងបានអញ្ជើញមកមើលចាត់ការឲ្យដាក់ភ្លើងអគ្គិសនី ព្រមទាំងចេញថ្លៃភ្លើងឲ្យប្រើក្នុងឱកាសបុណ្យនេះដរាបដល់ថ្ងៃបង្ហើយ ។ ក្នុងវេលារាត្រីទាំង ២ ក៏មានរស្មីភ្លើងពណ៌ស ក្រហម លឿង ខៀវ ភ្លឺចិញ្ចែងចិញ្ចាចចោលរស្មីផ្លាលប្រវាត់ប្រទាក់រកគ្នា, នៅខ្លោងទ្វារពេងមានផែនក្ដារអក្សរតួធំៗ ដែលបិទក្រដាសពណ៌មាសបញ្ចាំងស្រមោលភ្លើងភ្លឺអស្ចារ្យល្អមើលជាទីបំផុត ។ ឯអក្សរនៅផែនក្ដារនោះជាសេចក្ដីសូមប្រគេនពរដល់សម្ដេចព្រះមហាសុមេធាធិបតី ។

## ពិធីរៀបបុស្បុកខាងក្នុងកំពែងព្រះវិហារ

ក្នុងកំពែងវិហារខាងក្នុង ត្រង់ទីលានខាងកើតវិហារ មានបុស្បុក១ សម្រាប់សម្ដេចស្រង់ទឹក ដែលពួកជាងអ្នកចីកការបានរចនាកសាងឡើង

ដំណួអស្ចារ្យ, មានជើងក្រោស ៣ ជាន់ទ្រត្រួបុស្បក, មានកំពស់តាំងពីជើងកោសរហូតដល់កំពូលបុស្បកទាំងអស់ ៧ ម៉ែត្រ, មានជណ្តើរនិងបង្កាន់ដៃគ្រប់ទាំង ៤ ជ្រុង, មានឆត្រត្រួតគ្រប់ជ្រុងទាំង ៤ ។ ត្រួបុស្បកនោះក៏មានសន្ទិយាសំយុងចុះមកគ្រប់ទាំង៤ជ្រុង ។ ឯផ្ចាំងសន្ទិយានោះសុទ្ធស្ទើងតែបិទរំលេចដោយផ្កាចន្ទន៍កយផ្កាយ ដែលរចនាអំពីក្រដាសពណ៌មាស ។

## បារាំ ៣ ខ្នង ខាងក្នុងកំពែងព្រះវិហារ

ខាងក្នុងកំពែង នៅខាងស្តាំវិហារ មានបារាំធំ ១ ខ្នងសម្រាប់ជាព្រះពន្លាថ្វាយព្រះករុណា ជាម្ចាស់ជីវិតនិងលោកកុម្ម៉ៃស្សែរព្រមទាំងអស់លោកគណៈរដ្ឋមន្ត្រីដែលទ្រង់ស្តេច - អញ្ជើញមកប្រថាប់ - អង្គុយជាអធិបតីក្នុងពិធីបុណ្យស្រង់ទឹកនេះ ។ នៅខាងឆ្វេងវិហារ មានបារាំធំ ១ ខ្នងទៀតសម្រាប់ប្រគេនព្រះសង្ឃរាជាគណៈមេគណ អនុគណ និងលោកចៅអធិការ ។ បារាំធំទាំងពីរខ្នងនេះមានរបៀបរៀបចំដូចៗគ្នាគឺ មានផ្កាកម្រងវែងៗ ចងខ្វែងកាត់ប្រទាក់គ្នាដល់ទីបំផុតបារាំ ព្រមទាំងផ្កាកម្រងវង់មូលក៏មាន, ជា ៣ ជ្រុងក៏មាន, ជាផ្ការំយោលក៏មាន ដែលចងព្យួរសំយុងចុះជេរជាសក្នុងបារាំទាំង២ខ្នងនោះ ។ សសរបារាំទាំងអស់សុទ្ធតែស្រោបដោយស្លឹកដៃជនិងស្លឹកទន្សែ, មានទង់ជ័យបីៗ បោះបំពាក់ភ្ជាប់គ្រប់សសរបារាំ ព្រមទាំងជើងផ្កា - ជើងកូនឈើក៏រៀបចំឲ្យត្រូវគ្នាជាគូៗ រៀងកាយតាមសសរបារាំជួរមុខ ។ ក្នុងបារាំនោះក៏សុទ្ធតែក្រាលព្រំខ្សែវែងៗ ទាំងអស់ ។ នៅផ្លូវជញ្ជាំងព្រះវិហារចំពីខាងកើត មានបារាំតូច ១ ខ្នង គេ

រៀបតុបតែងគ្រឿងសក្ការបូជាដ៏វិចិត្រ គួរជាទីជ្រះថ្លាដូចរោងតាំងនៅផ្លាក្រៅកំពែងព្រះវិហារនោះដែរ ៗ ប៉ារ៉ាំតូចនេះក៏មានតួអក្សរធំៗ ដែលយកក្រដាសពណ៌មាសកាត់ជាតួអក្សរបិទនៅផ្ទាំងដាក់អំពីខាងមុខ ប្រកាសដំណឹងថា "បុណ្យសម្ពោធសមណស័ក្តិនិងបុណ្យចំរើនព្រះជន្មសម្តេច" ៗ

## ហេតុដ៏អស្ចារ្យនៅថ្ងៃចូលបុណ្យ

នៅថ្ងៃពុធ ៩ កើតខែពិសាខជាថ្ងៃចូលបុណ្យនោះ ក្នុងវេលារាត្រីមានពន្លឺភ្លើងចិញ្ចែងចិញ្ចាច តាំងពីពេលព្រលប់ដរាបដល់ពេលអរុណរះ ៗ ក្នុងថ្ងៃនោះ មានភ្លៀងបង្អុរចុះមកយ៉ាងច្រើន តាំងពីម៉ោង ៦ ព្រលប់ដល់ម៉ោង ៨ កន្លះទើបរាំង, តែភ្លៀងនោះគួរឲ្យនឹកអស្ចារ្យណាស់ គឺបង្អុរមកដោយស្ងប់ស្ងៀមឥតមានខ្យល់សោះ, ឯរោងតាំងតុទីង គ្រឿងតាំងទាំងអស់ឥតមានដាប់ដាបខូចខាតរខិតដោយភ្លៀងនោះឡើយ ៗ ក្នុងរាត្រីនោះសូម្បីមានភ្លៀងបង្អុរធ្លាក់មកជាឧបស័គ្គប៉ុណ្ណោះហើយក៏ដោយ, ក៏នៅតែមានពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថ ចូលមកមើលដើរជាសចង្អៀតណែនណាន់តាន់តាប់ ទាំងខាងក្នុងកំពែងព្រះវិហារ និងខាងក្រៅព្រះវិហារ ៗ

## ថ្ងៃទី ១ គឺថ្ងៃពុធ ៩ កើតខែពិសាខ

ម៉ោង ១៨ គឺម៉ោង ៦ រសៀល – គេរៀបគ្រឿងសក្ការបូជាក្នុងព្រះវិហារ, អុជប្រទីបផ្កាលាខាងក្នុងព្រះវិហារនិងខាងក្រៅព្រះវិហារ ៗ

ម៉ោង ២០ គឺម៉ោង ៨ យប់ – ពុទ្ធបរិស័ទជួបជុំគ្នានមស្សការ

ព្រះរតនត្រ័យ, និមន្តព្រះសង្ឃ ៦៩ អង្គ សុទ្ធតែព្រះរាជាគណៈ មេគណ អនុគណ និងចៅអធិការ ចំរើនព្រះបរិត្តក្នុងព្រះវិហារដើម្បីប្រគេនពរសិរីសួស្តីដល់សម្តេចព្រះមហាសុមេធាធិបតី ។ លុះចប់កិច្ចចំរើនព្រះបរិត្តហើយ ព្រះមុនីកោសល ចៅអធិការវត្តពោធិ៍វាល មេគណខេត្តបាត់ដំបង តំណាងព្រះសង្ឃ ៦៩ អង្គផ្តើមថ្លែងសេចក្តីប្រគេនពរដោយសេចក្តីត្រេកអរដ៏ក្រៃលែងចំពោះសម្តេចដែលទើបបានឡើងសមណស័ក្តិខ្ពស់បំផុត ។ បន្ទាប់អំពីនេះ, សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា ចៅអធិការវត្តលង្កា ប្រកាសសេចក្តីចំពោះព្រះសង្ឃទាំងអស់ថា "ខ្ញុំព្រះករុណាមានសេចក្តីត្រេកអរជាទីបំផុត ចំពោះព្រះមហាសុមេធាធិបតី ដែលទើបបានឡើងឋានៈជាសម្តេចនេះ គួរជាទីពេញចិត្តនៃពុទ្ធបរិសទ្យទាំងអស់ ដោយសម្តេចអង្គនេះជាព្រះថេរៈមានប្រាជ្ញាវាងវៃ ប្រកបដោយសមត្ថភាពនិងចរិយាធម៌ដ៏ប្រសើរ ដែលគួរព្រះសង្ឃយកគម្រប់តាមបានដោយពិត" ។ រួចសម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា ប្រគេនពរសព្ទសាធុការចំពោះសម្តេចដូចព្រះមុនីកោសលដែរ ។

លុះដល់ទីបំផុតថេរវាចានៃព្រះមុនីកោសល និង សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សាហើយ, សម្តេចព្រះមហាសុមេធាធិបតី បានថ្លែងតបថេរវាចាវិញថា "ខ្ញុំព្រះករុណា ដែលបានស្តាប់ថេរវាចាអម្បាញ់មិញនេះ មានសេចក្តីត្រេកអរសាទរដ៏មហិមាចំពោះសម្តេចព្រះធម្មលិខិត ព្រមទាំងព្រះសង្ឃរាជាគណៈ មេគណ អនុគណ និងចៅអធិការទាំងអស់ ដែល

បានទិមន្តមកជួបជុំគ្នាក្នុងពិធីបុណ្យនេះ ដើម្បីសំដែងមិត្តភាពចំពោះពុទ្ធបរិសទ្យ ឲ្យមានសេចក្ដីសាមគ្គីសៅវ៉ែងឆ្ងាយតទៅ » ។

បន្ទាប់អំពីនោះ មានអ្នកធ្មុះកុននៅខាងជើងព្រះវិហារតាំងពីម៉ោង ១០ រហូតដល់ម៉ោង ២ ទើបឈប់ ។

## ថ្ងៃទី ២ គឺថ្ងៃព្រហស្បតិ៍ ១០ រោចខែពិសាខ

ម៉ោង ៧ និង ៣០ នាទីពេលព្រឹក – សម្ដេចព្រះមហាសុមេធាធិបតីនិងព្រះសង្ឃរាជាគណៈបានានុក្រម ព្រមទាំងមន្ត្រីសង្ឃជាមេគណៈអនុគណក្នុងព្រះរាជអាណាចក្រ មួយអន្លើនឹងពួកពុទ្ធបរិសទ្យ រង់ចាំទទួលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងលោកកុម្មវិស៊្យេរសាធារណរដ្ឋបារាំង នៅទីបារាំខាងមុខព្រះវិហារ ។

ម៉ោង ៨ – ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងលោកកុម្មវិស៊្យេរស្ដេចមក – អញ្ជើញមកដល់មុខព្រះវិហារ មានទាហានក្រុមរក្សាព្រះអង្គនិងក្រុមភ្លេងតែព្រះរាជទ្រព្យចាំទទួលជាព្រះរាជកិត្តិយស រួចហើយស្ដេចមក – អញ្ជើញមកប្រថាប់នៅទីព្រះពន្លាខាងមុខព្រះវិហារ ដោយមានគណៈរដ្ឋមន្ត្រីនិងក្រុមប្រឹក្សាព្រះរាជអាណាចក្ររង់ចាំក្រាបថ្វាយបង្គំគាល់ក្នុងទីនោះផង ។

ម៉ោង ៨ និង ១០ នាទី – ព្រះពោធិវង្ស ហួត-តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់សូត្រសុន្ទរកថាថ្វាយសេចក្ដីអំពីប្រវត្តិរបស់សម្ដេច

ព្រះមហាសុមេធាធិបតីសង្ឃនាយក      ចំពោះព្រះករុណា ជាម្ចាស់ជីវិត (សុន្ទរកថានេះមាននៅខាងចុង) ។

ម៉ោង ៨ នឹង ៣០ នាទី – សម្តេចឡើងគង់លើបុស្បុកបែរព្រះភ័ក្ត្រទៅទិសបូព៌ា ព្រះសង្ឃរាជាគណៈ ឋានានុក្រមនិងមន្ត្រីសង្ឃ មេគណ អនុគណគ្រប់ខេត្ត សូត្រជយន្តោ ប្រគេនជយមង្គលចំពោះសម្តេចព្រះមហាសុមេធាធិបតី ។

ព្រះករុណា ជាម្ចាស់ជីវិតនឹងលោកកុម្ភៈសៀវ ស្តេច-អញ្ជើញទៅលើបុស្បុក ប្រោះសុគន្ធវារីលើព្រះហស្តខាងស្តាំនៃសម្តេចព្រះមហាសុមេធាធិបតី រួចស្តេចចុះ អញ្ជើញចុះមកវិញប្រថាប់នៅព្រះពន្លាដដែល ។

លំដាប់ពីនោះ សម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិនឹងសម្តេចព្រះធម្មលិខិតឧត្តមប្រីក្សាគណៈមហានិកាយ និមន្តឡើងទៅលើបុស្បុក ប្រោះសុគន្ធវារីលើព្រះហស្តស្តាំនៃសម្តេចព្រះមហាសុមេធាធិបតី រួចនិមន្តចុះមកគង់កន្លែងដដែលវិញ ។

សម្តេចព្រះមហាសុមេធាធិបតី ក្រោយដែលបានទទួលសុគន្ធវារីរួចហើយ និមន្តចុះពីបុស្បុកមកទទួលព្រះពរព្រះករុណា ជាម្ចាស់ជីវិតនឹងលោកកុម្ភៈសៀវ ។ បន្ទាប់មក សម្តេចព្រះមហាសុមេធាធិបតីថ្លែងសុន្ទរកថាថ្វាយព្រះពរតបព្រះករុណា ជាម្ចាស់ជីវិតនឹងលោកកុម្ភៈសៀវ (សុន្ទរកថានេះមាននៅខាងចុង) ។

ម៉ោង៩ និង ៤០ នាទី — ព្រះករុណា ជាម្ចាស់ជីវិតនិងលោកកុម្ម៉ៃសៀរ នៃសាធារណរដ្ឋបារាំង ស្ដេចត្រឡប់ - អញ្ជើញត្រឡប់ទៅវិញ ។

ម៉ោង ៩ និង ៤៥ នាទី — ពុទ្ធបរិសទ្យទាំងបព្វជិតទាំងគ្រហស្ថ និមន្តសម្ដេចព្រះមហាសុមេធាធិបតី ឲ្យគង់លើបុស្បុក ដើម្បីស្រង់ព្រះសុគន្ធវារីម្ដងទៀត ។ លុះស្រង់ស្រេចហើយ និមន្តចុះមកវិញ ។ ក្នុងខណៈនោះ ព្រះទេពសត្ថា សូរ - ហាយ ក្រមជំនុំព្រះត្រៃបិដក សូត្រសុន្ទរកថាជាតំណាងព្រះសង្ឃរាជាគណៈ មេគណ អនុគណនិងចៅអធិការទាំងអស់ ប្រគេនពរចំពោះសម្ដេចដោយសេចក្ដីត្រេកអរចំពោះកិត្តិយសនៃសម្ដេច ( សុន្ទរកថានេះមាននៅខាងចុង ) ។

បន្ទាប់ពីនោះមក សម្ដេចព្រះមហាសុមេធាធិបតី បានថ្លែងតបថា " ខ្ញុំព្រះករុណា កាលបើបានស្ដាប់សុន្ទរកថាអម្បាញ់មិញនេះហើយ ខ្ញុំមានសេចក្ដីសោមនស្សដែរ តែខ្ញុំមិនឡើងបញ្ញោរដោយក្លែងខ្លួនតាមសុន្ទរកថាដែលសរសើរអំពីគុណសម្បទនោះទេ " ។ រួចសម្ដេចមានថេរវាចាសំណេះសំណាលចំពោះព្រះសង្ឃនិងគ្រហស្ថ ទាំងប្រគេនពរជូនពរឲ្យកើតសេចក្ដីរីករាយក្នុងការបុណ្យនេះដោយសង្ខេប ៗ ។

ម៉ោង ១១ និង ២០ នាទី — ប្រគេនចង្ហាន់ដល់ព្រះសង្ឃ ៦៩ អង្គដែលនិមន្តចំរើនព្រះបរិត្តព្រមទាំងមន្ត្រីសង្ឃ រាជាគណៈ មេគណ អនុគណ និងចៅអធិការ ដែលនិមន្តមកអំពីគ្រប់ខេត្តក្នុងព្រះរាជអាណាចក្រ ។

ម៉ោង ១៩ ទឹង ៣០ នាទី - ពួកពុទ្ធបរិសទ្យនាំគ្នានមស្សការបំពោះព្រះរតនត្រ័យ រួចហើយនិមន្តសម្តេចព្រះមហាសុមេធាធិបតីទេសនា ។ សម្តេចបានព្រមទទួលនិមន្តដោយសេចក្តីអនុគ្រោះចំពោះពុទ្ធបរិសទ្យ ។ ធម្មទេសនាក្នុងពេលនោះដាក់វិទ្យុ ខ្សែសនសព្ទបំពងសំឡេងលាន់ឮគ្រាំងគ្រអោរ ។

ធម្មទេសនានៃសម្តេចក្នុងពេលនោះ ក៏ពីរោះក្បោះក្បាយអស្ចារ្យ ចម្លែកណាស់ជាងពីកាលមុនៗមក ។ ពុទ្ធបរិសទ្យទាំងបព្វជិតទាំងគ្រហស្ថ សឹងតែលាន់មាត់សរសើរគ្រប់ៗគ្នា ។ អ្នកខ្លះពោលថា "ធម្មទេសនានេះទើបសមជាធម្មទេសនារបស់សម្តេចមែន" ។ អ្នកខ្លះសរសើរថា "ទេសនានេះពីរោះអ្វីម្ល៉េះទេ"! លុះចប់ធម្មទេសនាហើយ អ្នកខ្លះពោលដោយទឹកស្តាយថា "ធម្មទេសនានេះ បើកុំកាលបញ្ចប់ សូម្បីទេសមួយម៉ោងឬពីរម៉ោងទៅទៀតក៏មិនធុញទ្រាន់" ។

ពួកពុទ្ធបរិសទ្យទាំងអស់ដែលមកធ្វើបុណ្យពិធីស្រង់ទឹកនេះ ច្រើនតែលាន់មាត់សរសើរថា "ពិធីបុណ្យនេះជាបុណ្យធំថ្កុំថ្កើងរុងរឿងដោយមានរបៀបគ្រប់យ៉ាងឥតខ្ចោះត្រង់ណា ជាទីជ្រះថ្លាពីកាយចិត្តដ៏ក្រៃលែង" ។

លុះព្រឹកឡើងថ្ងៃ ១១ កេចខែពិសាខ - ម៉ោង ៧ ទឹង ៣០ នាទី, ពុទ្ធបរិសទ្យចាត់ចែងប្រគេនយាគូដល់ព្រះសង្ឃ ជាការបង្ហើយបុណ្យក្នុងវេលានោះ ។ (មានត)

## បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

របស់

# ក្រសួងធម្មការ

(តមក)

---

សញ្ញាប័ត្រលេខ ៦៣៤ ចុះថ្ងៃពុធ ១ កើតខែចេត្រឆ្នាំជូតសំរិទ្ធិស័ក ព.ស. ២៤៩១ តាំងលោកគ្រូ តុក-សាន់ នាមឆាយា សុធម្មប្បញ្ញោ កើតឆ្នាំមមី អាយុ ៣១ វស្សា ១១ ជាចៅអធិការវត្តទ្រាំង ឃុំព្រះធាតុ ស្រុកកំពង់ត្របែក ខែត្រព្រៃវែង ។

សញ្ញាប័ត្រលេខ ៦៣៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យស-សួរ នាមឆាយា សង្ឃរក្ខិត កើតឆ្នាំឆ្លូវ អាយុ ៤៨ វស្សា ២៨ ជាគ្រូសូត្រស្តាំ វត្តធម្មកេត្តិ ឃុំគោកគង់ ស្រុកកញ្ជ្រៀច ខែត្រព្រៃវែង ។

សញ្ញាប័ត្រ លេខ ៦៣៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ែន-ប៊ុប នាមឆាយា ឥន្ទជោត កើតឆ្នាំថោះ អាយុ ៤៦ វស្សា ២៥ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៦៣៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គួប-គង់ នាមឆាយា ព្រហ្មប្បញ្ញោ កើតឆ្នាំថោះ អាយុ ៣៤ វស្សា ១០ ជាចៅអធិការវត្តកំពង់សំរិទ្ធ ឃុំមៀន ស្រុកព្រៃឈរ ខែត្រកំពង់ចាម ។

សញ្ញាប័ត្រលេខ ៦៣៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ខែក - ឈិន នាមធាយា ឥន្ទត្ថេរប្បញ្ញា កើតឆ្នាំមមី អាយុ ៣១ វស្សា ១១ ជាគ្រូសូត្រស្តាំ វត្តត្រពាំងព្រះ ឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៦៣៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម - គី នាមធាយាធម្មជោត កើតឆ្នាំវក អាយុ ២៩ វស្សា ៩ ជាចៅអធិការវត្តព្រះបន្ទូរឫស្សី ឃុំក្រាំងស្គា ស្រុកទឹកផុះ ខេត្តកំពង់ឆ្នាំង ។

សញ្ញាប័ត្រលេខ ៦៤២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហង់ - ប៉េង នាមធាយា វិសុទ្ធិប្បញ្ញា កើតឆ្នាំ គ.ស. ១៩០៥ អាយុ ៤៤ វស្សា ២២ ជាចៅអធិការវត្តសិរីសុទ្ធារាមក្រោម ឃុំក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ ។

សញ្ញាប័ត្រលេខ ៦៤៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហ៊ុន - ញឹម នាមធាយា ឥន្ទប្បញ្ញា កើតឆ្នាំជូត អាយុ ៣៨ វស្សា ១៧ ជាចៅអធិការនៅវត្តក្បៀងកាយ ឃុំក្បៀងកាយ ស្រុកកញ្ជៀច ខេត្តព្រៃវែង ។

សញ្ញាប័ត្រ លេខ ៦៤៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជេត - យឹម នាមធាយា សុវណ្ណត្ថេរ កើតឆ្នាំ ព.ស. ២៤៤៩ អាយុ ៤៣ វស្សា ២២ ជាចៅអធិការវត្តបារាយណ៍ ឃុំបារាយណ៍ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៦៤៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មួយ-ចិល នាមធាយា ធម្មត្ថេរ កើតឆ្នាំ ព.ស. ២៤៦២ អាយុ ៣០ វស្សា ៧ ជាគ្រូសូត្រស្តាំនៅវត្តស្រោងស្រះឡៅ ឃុំបឹងណាយ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៤៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុង-សាយ នាមធាយា សុវណ្ណត្ថេរ កើតឆ្នាំច អាយុ ២៨ វស្សា ៧ ជាចៅអធិការ នៅវត្តស្តៅ ឃុំព្រែកល្ហៀង ស្រុកព្រៃវែង ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៦៥០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ផូរ-កុយ នាមធាយា ចន្ទត្ថេរ កើតឆ្នាំពេង អាយុ ៥៨ វស្សា ៣៥ ជាចៅអធិការនៅវត្តព្រែកទ្នោង ឃុំព្រែកទ្នោង ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៥១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាន់-ចិន នាមធាយា បញ្ញាជោត កើតឆ្នាំខាលអាយុ ៤៨ វស្សា ២៧ ជាគ្រូសូត្រស្តាំ នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៥២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ែន-ឌុល នាមធាយា បញ្ញាកេសរ កើតឆ្នាំរកា អាយុ ២៩ វស្សា ៩ ជាចៅអធិការនៅវត្តកអណ្តើក ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។

(មានត